GADC
អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា
Gender and Development for Cambodia

# MEN'S DIALOGUE
# កិច្ចពិភាក្សាបុរស

## វិធីសាស្ត្រនៃការអនុវត្តកិច្ចពិភាក្សាបុរសរបស់ អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា



WWW.GADC.ORG.KH

GADC
អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា
Gender and Development for Cambodia

# សេចក្តីថ្លែងអំណរគុណ

ក្នុងនាមអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមការងារទាំងអស់មកពីគ្រប់កម្មវិធីនៅក្នុងស្ថាប័ន រួមមានកម្មវិធីទំនាក់ទំនងសហគមន៍ (CO) កម្មវិធីតស៊ូមតិ និងបណ្តាញ (ANP) កម្មវិធីបណ្តាញបុរសកម្ពុជា (CMN) និងកម្មវិធីអប់រំបែបហ្វេមមីនីស្ត (FEP) ដែលបានយកពេលវេលាដ៏មានតម្លៃរបស់ខ្លួនដើម្បីចូលរួមយ៉ាងសកម្មក្នុងការប្រជុំពិភាក្សាពិគ្រោះយោបល់ និងរួមចំណែកក្នុងការរៀបរៀង និងធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំនេះឡើងវិញ។

សូមថ្លែងអំណរគុណចំពោះអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ ជាតិ និងអន្តរជាតិ ជាពិសេស ស្ថាប័នដៃគូនៃគម្រោងពង្រឹងសមត្ថភាពអង្គការសង្គមស៊ីវិលដើម្បីសិទ្ធិកុមារ តាមរយៈអង្គការ Save the Children ប្រចាំប្រទេសកម្ពុជា ដែលបានរួមចំណែកក្នុងការគាំទ្រទាំងធនធានថវិកា និងការផ្តល់ធាតុចូលដើម្បីធ្វើឱ្យដំណើរការនៃការធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំនេះប្រព្រឹត្តទៅបានកាន់តែគ្រប់ជ្រុងជ្រោយ។

## អំពីអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)

អង្គការយេនឌ័រ និងអភិវឌ្ឍដើម្បីកម្ពុជា ហៅកាត់ថា ហ្គេតស៊ី (GADC) គឺជាអង្គការក្នុងស្រុក មិនរកកម្រៃ និង មិនធ្វើនយោបាយ បានបង្កើតឡើងដោយក្រុមស្ត្រីបន្ទាប់ពីការប្រារព្ធសន្និសីទជាតិលើកទីមួយស្តីពីយេនឌ័រ និងការអភិវឌ្ឍនៅកម្ពុជាក្នុងឆ្នាំ ១៩៩៧ ដើម្បីលើកកម្ពស់សិទ្ធិស្ត្រីគ្រប់ចម្រុះភាពក្នុងការទទួលបានសមភាពយេនឌ័រ និងសិទ្ធិមនុស្ស។ ចាប់តាំងពីពេលនោះមកអង្គការ GADC បានកសាងកេរ្តិ៍ឈ្មោះរបស់ខ្លួនដោយមានសំឡេងនាំមុខគេលើវិស័យសមភាពយេនឌ័រនៅកម្ពុជា។ អង្គការ GADC បានធ្វើការអស់រយៈពេលជាងម្ភៃឆ្នាំមកហើយជាមួយស្ត្រី បុរស និងយុវជនគ្រប់អត្តសញ្ញាណដើម្បីពង្រឹងការចូលរួមរបស់ស្ត្រី និងក្មេងស្រីគ្រប់ចម្រុះភាពក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដែលមានឥទ្ធិពលដល់ជីវិតរស់នៅរបស់ពួកគេ ទាំងនៅក្នុងគ្រួសារ និងសហគមន៍ ក៏ដូចជាទទួលបានឱកាសសេដ្ឋកិច្ច ប្រកាន់យកតួនាទីជាអ្នកដឹកនាំ បង្កើនការចូលរួមរបស់ស្ត្រីក្នុងដំណើរការនយោបាយ និងសាធារណៈ ជំរុញរដ្ឋាភិបាលឱ្យទទួលខុសត្រូវចំពោះតួនាទីរបស់ខ្លួនក្នុងការបង្កើតសមភាពយេនឌ័រ និងចាត់វិធានការដើម្បីបញ្ចប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ ព្រមទាំងការរើសអើងចំពោះស្ត្រី និងក្មេងស្រីនៅក្នុងសហគមន៍ តាមរយៈការសហការជាមួយអាជ្ញាធរមូលដ្ឋាន រដ្ឋបាលថ្នាក់កណ្តាល ក៏ដូចជានៅក្នុងវេទិកាថ្នាក់តំបន់ និងអន្តរជាតិ។

បោះពុម្ពផ្សាយដោយ៖ អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)
គាំទ្រការបោះពុម្ពដោយ៖ ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (SIDA) តាមរយៈអង្គការ Save the Children ប្រចាំប្រទេសកម្ពុជា
សម្គាល់៖ ខ្លឹមសារក្នុងសៀវភៅណែនាំនេះ គឺជាទំនួលខុសត្រូវរបស់ GADC ទាំងស្រុង ។
សំណួរ និងមតិយោបល់អំពីសៀវភៅណែនាំ៖ អ៊ីម៉ែល Info@gadc.org.kh

# មាតិកា

១. សេចក្ដីផ្ដើម ..... 1
២. វិសាលភាព ..... 2
៣. អំពីកិច្ចពិភាក្សាបុរស ..... 3
៣.១ តើកិច្ចពិភាក្សាបុរសគឺជាអ្វី? ..... 3
៣.២ សារតានៃកិច្ចពិភាក្សាបុរស ..... 3
៣.៣ ហេតុអ្វីនាំឱ្យមានកិច្ចពិភាក្សាបុរស? ..... 3
៣.៤ តើអ្វីជាគោលដៅចំបងនៃកិច្ចពិភាក្សាបុរស? ..... 4
៤. ដំណើរការនៃកិច្ចពិភាក្សាបុរស ..... 4
៤.១ តើកិច្ចពិភាក្សាបុរសត្រូវរៀបចំបែបណា? ..... 4
៤.២ ទំហំនៃកិច្ចប្រជុំ និងអ្នកចូលរួម ..... 5
៤.៣ កន្លែងនៃកិច្ចប្រជុំ ..... 6
៤.៤ ពេលវេលានៃកិច្ចប្រជុំ ..... 7
៤.៥ ចំនួនវគ្គ ..... 7
៤.៦ ការកំណត់ និងរៀបចំប្រធានបទ ..... 8
៤.៧ ការបង្កើតកម្រងសំណួរដើម្បីធ្វើការឆ្លុះបញ្ចាំង ..... 10
៥. វិធីសាស្ត្រសម្របសម្រួលបែបហ្វេមមីនីស្ត ..... 11
៦. ការប្រុងប្រយ័ត្ននៅពេលពិភាក្សាអំពីភាពជាបុរស និងហ្វេមមីនីស្ត ..... 13
៧. ការសម្របសម្រួលកិច្ចពិភាក្សាបុរសតាមប្រព័ន្ធអនឡាញ ..... 13
៨. គោលការណ៍ និងក្រមសីលធម៌របស់អ្នកសម្របសម្រួល ..... 14
៨.១ ទំនួលខុសត្រូវផ្នែកសីលធម៌ ..... 14
៨.២ ការគ្រប់គ្រងព័ត៌មានរសើប ..... 14
៨.៣ កិច្ចការពារសុវត្ថិភាពកុមារ ..... 16
៨.៣.១ ឥរិយាបថត្រូវធ្វើ និងមិនត្រូវធ្វើក្នុងកិច្ចការពារសុវត្ថិភាពកុមារ ..... 17
៩. ការត្រួតពិនិត្យ និងការវាយតម្លៃ ..... 19

៩.១ គោលបំណងចម្បងនៃការត្រួតពិនិត្យ និងវាយតម្លៃ ........ 19
៩.២ នៅមុនពេលចាប់ផ្តើមកិច្ចពិភាក្សាបុរស ........ 19
៩.៣ ក្នុងអំឡុងពេលកិច្ចពិភាក្សាបុរស ........ 19
៩.៤ បន្ទាប់ពីកិច្ចពិភាក្សាបុរស ........ 20
៩.៥ សូចនាករ ........ 20

# ១. សេចក្តីផ្តើម

នៅក្នុងបរិបទប្រទេសកម្ពុជា វិសមភាពយេនឌ័រនៅតែមាន ហើយវាមិនមែនគ្រាន់តែជាបញ្ហារបស់ស្ត្រីប៉ុណ្ណោះទេ ប៉ុន្តែវាជាបញ្ហាសង្គមដែលប៉ះពាល់ដល់មនុស្សគ្រប់រូប រួមទាំងបុរសផងដែរ។ ការចាក់ឫសយ៉ាងជ្រៅនៃបទដ្ឋានសង្គមបែបប្រពៃណី និងជំនឿក្នុងប្រព័ន្ធបិតាធិបតេយ្យ បានជំរុញឱ្យវិសមភាពទាំងនេះបន្តតែងតាំងបុរសក្នុងតួនាទីគ្រប់គ្រង ជាអ្នករកចំណូលផ្គត់ផ្គង់ជីវភាពគ្រួសារ មានសិទ្ធិអំណាច ត្រួតត្រា គាបសង្កត់ ឬអាចប្រព្រឹត្តអំពើហិង្សាលើអ្នកជុំវិញខ្លួន ស្របពេលដែលដាក់កំហិត និងរឹតត្បិតឱកាស ក៏ដូចជាលទ្ធផលដែលស្ត្រី ក្មេងស្រី និងក្រុមអ្នកមានអត្តសញ្ញាណយេនឌ័រចម្រុះផ្សេងៗទៀតទទួលបាន។ នៅកម្ពុជា ស្ត្រីទទួលបានចំណូលតិចជាងបុរសប្រហែល ១៩% ពីការធ្វើការងារដូចគ្នា ហើយនៅតែមានសំឡេង ឬតំណាងតិចតួចនៅក្នុងតួនាទីជាអ្នកដឹកនាំ ការអប់រំ និងប្រព័ន្ធផ្សព្វផ្សាយ។[1] ម្យ៉ាងទៀត វត្តមានស្ត្រីមានត្រឹមតែ ១៣.៦% ប៉ុណ្ណោះនៃអាសនៈ រដ្ឋសភា ហើយពី ១៤.៩% ទៅ ១៥.៨% នៃមុខតំណែងប្រតិបត្តិជាន់ខ្ពស់ និង ១៧% នៃតួនាទីក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដែលឆ្លុះបញ្ចាំងពីឧបសគ្គជាប្រព័ន្ធកំណត់សិទ្ធិស្មើគ្នារបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការដឹកនាំ។[2] អតុល្យភាពទាំងនេះមិនកើតឡើងដោយចៃដន្យនោះទេ ប៉ុន្តែត្រូវបានបង្កើតឡើងដោយការរំពឹងទុករបស់សង្គមអំពីភាពជាបុរស អំណាច និងការគ្រប់គ្រង។ ជាមួយគ្នានេះផងដែរ បទដ្ឋានសង្គមទាក់ទងនឹងការរំពឹងទុកលើភាពជាបុរស បានធ្វើឱ្យមានការកើនឡើងនូវការប្រព្រឹត្តអំពើហិង្សា ការប្រព្រឹត្តអាកប្បកិរិយា និងរបៀបរស់នៅមិនល្អ ដែលអាចនាំទៅដល់បញ្ហាសុខភាព និងសុខុមាលភាពផ្លូវកាយ ឬផ្លូវចិត្តនានា ព្រមទាំងបង្កើនការចូលរួមរបស់បុរសនៅក្នុងក្រុមជ្រុលនិយមផ្សេងៗបង្កជាហានីភ័យ និងគ្រោះថ្នាក់ជាច្រើន។[3] ជាឧទាហរណ៍នៅកម្ពុជា ៣៦% នៃបុរសដែលធ្លាប់មានទំនាក់ទំនងដៃគូស្និទ្ធស្នាលត្រូវបានរាយការណ៍ថាប្រព្រឹត្តអំពើហិង្សាផ្លូវកាយ ឬផ្លូវភេទលើដៃគូស្និទ្ធស្នាលជាស្ត្រីនៅក្នុងជីវិតរបស់ពួកគេ ហើយ ៥០% នៃបុរសដែលធ្លាប់មានដៃគូទាំងអស់ធ្លាប់បានប្រព្រឹត្តអំពើហិង្សាផ្លូវចិត្ត ឬផ្លូវសេដ្ឋកិច្ចទៅលើដៃគូរបស់ខ្លួន។[4] បន្ថែមពីនេះទៀត ផ្នត់គំនិតទាក់ទងនឹងភាពជាបុរសទាំងនោះក៏បានបង្អាក់លទ្ធភាពរបស់បុរស និងក្មេងប្រុសក្នុងការឆ្លើយតបទៅនឹងបញ្ហាផ្លូវចិត្ត (ការបាក់ស្បាត) ដែលកើតចេញពីបទពិសោធន៍ឈឺចាប់នានានៅក្នុងជីវិតរបស់ពួកគេ។ បុរស និងក្មេងប្រុសដែលរងផលប៉ះពាល់ពីបទពិសោធន៍ដ៏តក់ស្លុតទាំងអស់

[1] United Nations Development Programme. (2021, March 11). UNDP launches report on Cambodia's gender wage gap. https://www.undp.org/cambodia/press-releases/undp-launches-report-cambodias-gender-wage-gap

[2] United Nations Cambodia. (2025). *Annual report on human rights and development in Cambodia, 2024*. https://cambodia.un.org/sites/default/files/2025-04/ARR2024_Cambodia_Final.pdf

[3] Slegh, H., Spielberg, W., & Ragonese, C. (2021). *Masculinities and male trauma: Making the connections*. Promundo-US.

[4] UNFPA Cambodia. (2023, December 1). Harmful social & gender norms that drive gender-based violence in Cambodia (40 pp.). United Nations Population Fund Cambodia. https://cambodia.unfpa.org/sites/default/files/pub-pdf/harmful_social_and_gender_norms_-_drive_gbv_in_cambodia.pdf

នោះមានអារម្មណ៍ប៉ះទង្គិច និងរងគ្រោះខ្លាំង ដោយសារតែផ្នត់គំនិតនៃភាពជាបុរសទាំងនោះមិនដែលបានបង្រៀនពួកគេឱ្យដោះស្រាយបញ្ហាទាក់ទងនឹងអារម្មណ៍ដែលខ្លួនកំពុងតែជួបប្រទះឡើយ។
ដូច្នេះហើយ ការយល់ដឹងអំពីបរិបទ និងការចូលរួមរបស់បុរសគ្រប់ចម្រុះភាពគឺពិតជាចាំបាច់ណាស់ ដែលពួកគេសុទ្ធតែជាផ្នែកមួយនៃការកសាងសង្គមជាតិប្រកបដោយសមភាព សមធម៌ ការគោរព និងបរិយាបន្ន ដើម្បីខ្លួនឯងក៏ដូចជាមនុស្សគ្រប់ចម្រុះភាពដទៃទៀតនៅជុំវិញខ្លួន។ សំឡេង និងភាពជាសម្ព័ន្ធមិត្ត អ្នកតស៊ូមតិ និងជាភ្នាក់ងារនៃការផ្លាស់ប្តូរសង្គមជាវិជ្ជមានរបស់បុរស ពិតជាមានសារៈសំខាន់ណាស់សម្រាប់ការប្រឆាំងនឹងបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ ភាពចាក់ស្រេះនៃប្រព័ន្ធបិតាធិបតេយ្យ និងជំរុញការកសាងបាននូវសហគមន៍ដែលមានសុវត្ថិភាព និងសមភាពយេនឌ័រ។

## ២. វិសាលភាព

សេចក្តីណែនាំនេះត្រូវបានរៀបចំឡើងសម្រាប់គ្រូបង្គោលសម្របសម្រួល ឬអ្នកដែលមានបំណងចង់ក្លាយជាអ្នកសម្របសម្រួលហ្វេមមីនីស្ត[5] ឬស្ថាប័នដែលកំពុងតែស្វែងរកវិធីសាស្ត្រការអនុវត្តកិច្ចពិភាក្សាជាមួយក្រុមបុរសនៅក្នុងសកម្មភាពការងាររបស់ខ្លួន។ សេចក្តីណែនាំនេះអាចប្រើប្រាស់ជាឧបករណ៍សម្រាប់គាំទ្រការតាមដានវឌ្ឍនភាពបន្ទាប់ពីសកម្មភាព ឬការបណ្តុះបណ្តាល ឬការចូលរួមពីសហគមន៍ និងបង្កើតកន្លែងសម្រាប់ការឆ្លុះបញ្ចាំងយ៉ាងស៊ីជម្រៅ ជំរុញការជឿទុកចិត្ត សាមគ្គីភាព និងការតភ្ជាប់ទំនាក់ទំនងដ៏ល្អប្រសើរនៅក្នុងសហគមន៍ដែលជាផ្នែកមួយនៃគោលការណ៍របស់ហ្វេមមីនីស្ត។

សេចក្តីណែនាំនេះក៏ផ្តល់ការណែនាំអំពីការបង្កើតកន្លែងមួយដែលមានបរិយាបន្ន និងមានសុវត្ថិភាពដល់បុរសគ្រប់ចម្រុះភាព ដោយមិនរើសអើងចំពោះអត្តសញ្ញាណយេនឌ័រ ជាតិសាសន៍ សមត្ថភាព និន្នាការភេទ សាវតាកត្តាសេដ្ឋកិច្ចសង្គមផ្សេងៗ ដើម្បីចែករំលែកបទពិសោធន៍ បង្កើតការយល់ដឹងគ្នាទៅវិញទៅមក និងបង្កើតជាសំឡេងរួម ជាភ្នាក់ងារក្នុងការគាំទ្រដល់ការពង្រឹងភាពអង់អាចរបស់ស្ត្រី និងក្មេងស្រី ហើយក៏ជាផ្នែកមួយនៃការទប់ស្កាត់អំពើហិង្សាផងដែរ។ សេចក្តីណែនាំនេះអាចអនុវត្តនៅក្នុងបរិបទផ្សេងៗ ទាំងដោយជួបមុខផ្ទាល់ និងតាមប្រព័ន្ធអនឡាញ ហើយអាចបត់បែនទៅតាមវិស័យ មូលបទ ក្រុមអ្នកចូលរួម និងវប្បធម៌ផ្សេងៗ ស្របជាមួយនឹងការរក្សាគុណតម្លៃស្នូលនៃសុវត្ថិភាព បរិយាបន្ន និងការគោរព។

[5] ហ្វេមមីនីស្ត (Feminist) គឺជាបុគ្គលដែលមានជំនឿថា គ្រប់គ្នា (ស្ត្រី បុរស និងបុគ្គលគ្រប់អត្តសញ្ញាណយេនឌ័រចម្រុះទាំងអស់) ស័ក្តិសមនឹងទទួលបានសិទ្ធ ជម្រើស សមភាពនៃឱកាស ការទទួលបានឱកាស និងសមភាពនៃលទ្ធផលចុងក្រោយដែលទទួលបាន ដោយមិនផ្អែកលើ ភេទ អាយុ តំបន់រស់នៅ អត្តសញ្ញាណយេនឌ័រ និន្នាការភេទ ពិការភាព ពូជសាសន៍ ពណ៌សម្បុរ សាសនា ជនជាតិ សញ្ជាតិ ឬ អត្តសញ្ញាណដទៃផ្សេងទៀតឡើយ។

# ៣. អំពីកិច្ចពិភាក្សាបុរស

## ៣.១ តើកិច្ចពិភាក្សាបុរសគឺជាអ្វី?

"កិច្ចពិភាក្សាបុរស" គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពជាច្រើនផ្សេងទៀតនៃការចូលរួមរបស់បុរស ដែលវាជាព្រឹត្តិការណ៍ ឬសកម្មភាពមួយ ឬច្រើន សម្រាប់ឱ្យក្រុមបុរសមានឱកាសក្នុងការពិភាក្សា ផ្លាស់ប្តូរមតិយោបល់ និងឆ្លុះបញ្ចាំងពីបទពិសោធន៍ដែលទាក់ទងនឹងរឿងរ៉ាវផ្ទាល់ខ្លួន ក៏ដូចជាការងារ ទៅលើបញ្ហាភាពជាបុរស សមភាព ឬវិសមភាពយេនឌ័រដែលកើតឡើងក្នុងពេលបច្ចុប្បន្ន។ វាជាកិច្ចប្រជុំដែលរៀបចំឡើងជាលក្ខណៈបែបមិនផ្លូវការ សាមញ្ញ ប៉ុន្តែគិតគូរពីសុវត្ថិភាព និង សេរីភាពអ្នកចូលរួមដើម្បីអោយពួកគេអាចចែករំលែកដោយសកម្ម និងការគោរព។ កិច្ចពិភាក្សាបុរសនេះគឺផ្តោតសំខាន់លើការពិភាក្សាអំពីឬសគល់ និងផលប៉ះពាល់នៃរឿងរ៉ាវផ្ទាល់ខ្លួនរបស់ពួកគាត់ ដើម្បីស្វែងរកជម្រើសនៃដំណោះស្រាយសមស្រប ធានាថាមានការលើកកម្ពស់ភាពអង់អាចរបស់ស្រ្តី សមភាពយេនឌ័រ និងមានការអនុវត្តសកម្មភាពឆ្លើយតបបន្ទាប់ពីកិច្ចពិភាក្សានេះបានបញ្ចប់។

## ៣.២ សារៈតានៃកិច្ចពិភាក្សាបុរស

បណ្តាញបុរសកម្ពុជា (CMN)[6] គឺជាសម្ព័ន្ធនៃក្រុមបុរសមកពីមជ្ឈដ្ឋានចម្រុះត្រូវបានបង្កើតឡើងនៅកំឡុងឆ្នាំ ២០០០ ដែលបានប្តេជ្ញាចិត្តក្នុងការបញ្ចប់អំពើហិង្សាលើស្រ្តី និងការលើកកម្ពស់សមភាពយេនឌ័រនៅកម្ពុជា។ ចាប់តាំងពីឆ្នាំ ២០១៤ មក ក្រោមការសម្របសម្រួលពីអង្គការយេនឌ័រ និងការអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) ជាលេខាធិការដ្ឋានរបស់ខ្លួន បណ្តាញបុរសកម្ពុជាបានអនុវត្តវិធីសាស្រ្តកិច្ចពិភាក្សាបុរស ដែលជាវេទិកាមួយកៀរគរបុរសរួមគ្នាដើម្បីឆ្លុះបញ្ចាំងដោយបើកចំហអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ភាពជាបុរសដែលបង្កគ្រោះថ្នាក់ និងតួនាទីរបស់ពួកគេក្នុងការលើកកម្ពស់សមភាពយេនឌ័រ។ កិច្ចពិភាក្សានេះបង្កើតជាកន្លែងសុវត្ថិភាពសម្រាប់បុរសដើម្បីចែករំលែកបទពិសោធន៍ បញ្ហាប្រឈម និងមេរៀនដែលបានរៀនសូត្រ ព្រមទាំងរួមគ្នាកសាងចំណេះដឹង និងសមត្ថភាពរបស់ពួកគេឱ្យក្លាយជាអ្នកតស៊ូមតិសម្រាប់ការផ្លាស់ប្តូរនៅក្នុងគ្រួសារ និងសហគមន៍របស់ខ្លួន។ វិធីសាស្រ្តនេះបានក្លាយជាយុទ្ធសាស្រ្តសំខាន់សម្រាប់ការងារពាក់ព័ន្ធនឹងការចូលរួមរបស់បុរសដើម្បីជំរុញការផ្លាស់ប្តូរអាកប្បកិរិយា និងសង្គមជាវិជ្ជមានសម្រាប់រយៈពេលវែង ក្នុងចំណោមបុរសគ្រប់ចម្រុះភាពក្នុងបរិបទប្រទេសកម្ពុជា។

## ៣.៣ ហេតុអ្វីនាំឱ្យមានកិច្ចពិភាក្សាបុរស?

តាមរយៈបទពិសោធន៍ ការសង្កេត និងការសិក្សាស្រាវជ្រាវបានបង្ហាញឱ្យឃើញនូវវិសមភាពនៃអំណាចរវាងបុរស និងស្រ្តី នៅក្នុងសង្គមខ្មែរ ជាពិសេសនៅក្នុងតួនាទីដឹកនាំ ការចូលរួមក្នុងបញ្ហាសាធារណៈ ការធ្វើការ

---

[6] បណ្តាញបុរសកម្ពុជា ឬ Cambodian Men's Network (CMN) គឺជាសម្ព័ន្ធរបស់សកម្មជនបុរស និងអ្នកតំណាងមកពីមជ្ឈដ្ឋានផ្សេងៗគ្នា ទាំងសាសនា សហគមន៍ មុខរបរ អង្គការក្រៅរដ្ឋាភិបាល/សង្គមស៊ីវិល ជនជាតិភាគតិច និងជនជាតិដើមភាគតិចគ្រប់ចម្រុះភាព ដែលប្តេជ្ញាលុបបំបាត់អំពើហិង្សាលើស្រ្តី និងការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងសង្គមកម្ពុជា។

សម្រេចចិត្ត ក៏ដូចជាការប្រកបមុខរបរចិញ្ចឹមជីវិតគ្រួសារ ដែលនាំឱ្យមានអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក៏ដូចជាអំពើហិង្សាលើស្ត្រី។ បុរសនៅតែមានឱកាសច្រើនជាងស្ត្រី ក្នុងការទទួលស្គាល់ដោយសង្គម និង

វប្បធម៌លើតួនាទីការដឹកនាំគ្រួសារ សហគមន៍ និងនៅក្នុងសង្គម។ ម៉្យាងវិញទៀត បទពិសោធន៍នៃការកិច្ចពិភាក្សារបស់យេនឌ័រកាហ្វេជាមួយក្រុមស្ត្រីបានបង្ហាញថា ពួកគាត់មានការកើននូវចំនេះដឹង និងជំនាញនៅក្នុងការវិភាគលើបញ្ហាយេនឌ័រ ទំនុកចិត្តនៅក្នុងការទាមទារនូវការគោរព និងការពារសិទ្ធិ ក៏ដូចជាការគាំទ្រ និងសាមគ្គីភាពជាមួយស្ត្រីផ្សេងទៀត។ ទន្ទឹមនឹងនេះបញ្ហាប្រឈមនៅតែមាន នៅពេលឥទ្ធិពលរបស់បុរស និង កង្វះខាតការយល់ដឹង ការចូលរួម និងការឆ្លុះបញ្ចាំងរបស់ពួកគេលើបញ្ហាទាក់ទងនឹងយេនឌ័រ ដែលនៅតែរាំងខ្ទប់ដល់ដំណើរការកសាងសង្គមគ្រួសារ និង សង្គមជាតិប្រកបដោយសមភាពយេនឌ័រ។ ដូច្នេះការបង្កើតនូវកន្លែង ឬកិច្ចប្រជុំពិភាក្សាដែលមានតែអ្នកចូលរួមជាបុរស ត្រូវបានគេមើលឃើញថាអាចនាំឱ្យបុរសផ្តល់មតិយោបល់ និងចែករំលែករឿងរ៉ាវផ្ទាល់ខ្លួន ព្រមទាំងរឿងរ៉ាវដែលអាចធ្វើឱ្យមានផលជះជាវិជ្ជមានទាក់ទងនឹងយេនឌ័រផ្សេងទៀតបានច្រើនជាងមុន។ ការចាប់ផ្តើមនៃការចែករំលែកនូវរឿងរ៉ាវនេះហើយដែលអាចនាំឱ្យមានការឆ្លុះបញ្ចាំង និងពិភាក្សា នាំឱ្យមានការផ្លាស់ប្តូរជាយូរអង្វែង ឆ្ពោះទៅរកនិរន្តរភាព។

### ៣.៤ តើអ្វីជាគោលដៅចំបងនៃកិច្ចពិភាក្សាបុរស?

គោលដៅជាក់លាក់នៃការរៀបចំកិច្ចពិភាក្សាបុរសមានដូចខាងក្រោម៖

- ជំរុញនិងកសាងទំនុកចិត្តអោយក្រុមបុរសពិភាក្សានូវរឿងរ៉ាវបញ្ហាផ្ទាល់ខ្លួន ជាមួយបុរសផ្សេងទៀត ដើម្បីឆ្លុះបញ្ចាំង បញ្ហាភាពជាបុរសរបស់ពួកគាត់ ដែលមានទំនាក់ទំនងនឹងបញ្ហាយេនឌ័រដទៃទៀតកំពុងតែកើតមាននាពេលបច្ចុប្បន្ន ។
- បង្កើនចំនេះដឹង និងសមត្ថភាពសម្រាប់ក្រុមបុរសក្នុងការឆ្លុះបញ្ចាំង វិភាគ និងចូលរួមចំណែកយ៉ាងសកម្មនៅក្នុងការឆ្លើយតបនឹងបញ្ហាយេនឌ័រ ក៏ដូចជាធ្វើឱ្យមានសមភាពយេនឌ័រតាមរយៈការចែករំលែក ផ្លាស់ប្តូរព័ត៌មានស្តីអំពីសិទ្ធិ ច្បាប់ គោលនយោបាយដែលទាក់ទងនឹងបញ្ហាយេនឌ័រ។
- ពន្លាតនូវបុព្វសិទ្ធិ និងអំណាចរបស់បុរស ដើម្បីឱ្យឃើញពីវិសមភាពនៅក្នុងបរិបទដែលខ្លួនរស់នៅ។
- ជំរុញអោយក្រុមបុរសបង្កើតផែនការសកម្មភាព និង ស្វែងរកជម្រើសដំណោះស្រាយលើរឿងរ៉ាវបញ្ហាផ្ទាល់ខ្លួន ដោយផ្តោតលើការឆ្លុះបញ្ចាំងពីភាពជាបុរស ដែលសង្គមកំណត់ឱ្យ។

## ៤. ដំណើរការនៃកិច្ចពិភាក្សាបុរស

### ៤.១ តើកិច្ចពិភាក្សាបុរសត្រូវរៀបចំបែបណា?

ដោយហេតុថាកិច្ចពិភាក្សាបុរសជាកិច្ចប្រជុំបែបឆ្លុះបញ្ចាំងដែលមិនមានលក្ខណៈផ្លូវការ ដូច្នេះការរៀបចំកិច្ចពិភាក្សាបុរសត្រូវមានសភាពប្រកបដោយមេត្រីភាពសម្រាប់អ្នកចូលរួមនៅក្នុងការជជែក។ នោះមានន័យថាបង្កភាពងាយស្រួលដល់អ្នកចូលរួមនៅក្នុងការបញ្ចេញមតិយោបល់ដោយមិនមានភាពភ័យខ្លាច ឬការ

រៀបចំខ្លួនជាផ្លូវការឡើយ។ ព្រឹត្តិការណ៍ ឬកិច្ចប្រជុំកិច្ចពិភាក្សាបុរសដែលមានប្រសិទ្ធភាព គឺជាកិច្ចប្រជុំដែលប្រព្រឹត្តទៅជាបន្តបន្ទាប់ មិនមែនតែមួយដងនោះទេ។ កិច្ចប្រជុំនេះនឹងនាំឱ្យអ្នកចូលរួមមានឱកាសចូលរួមលើសពីមួយដង ដែលអាចនាំឱ្យពួកគេមានពេលវេលាកសាងទំនាក់ទំនង និងទំនុកចិត្តជាមួយអ្នកសម្របសម្រួល ក៏ដូចជាអ្នកចូលរួមផ្សេងទៀតផងដែរ។

តាមរយៈការស្រាវជ្រាវលើការសិក្សា និងការផ្លាស់ប្តូរអាកប្បកិរិយារបស់មនុស្សពេញវ័យបានបង្ហាញថា កិច្ចប្រជុំតែ១វគ្គ គឺកម្របង្កើតបាននូវការផ្លាស់ប្រែយូរអង្វែង។ ការសិក្សាលើបន្ទាត់ខ្សែកោងនៃការភ្លេចភ្លាំងបង្ហាញថា ចំណេះដឹងនឹងរលាយបាត់យ៉ាងឆាប់រហ័សដោយគ្មានការរំលឹក ដែលមានន័យថាអ្នកចូលរួមទទួលបានការយល់ដឹងច្រើនពីការត្រឡប់ទៅសិក្សាទស្សនៈដដែលៗក្នុងចន្លោះពេលណាមួយ។[7] ទ្រឹស្តីសិក្សាពីសង្គមក៏បានបញ្ជាក់បន្ថែមថា មនុស្សរៀនមិនត្រឹមតែពីមេរៀនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពីការសង្កេតលើអ្នកដទៃ ការផ្លាស់ប្តូរបទពិសោធន៍ និងការអនុវត្តជំនាញក្នុងបរិបទជីវិតពិត។[8] ស្រដៀងគ្នានេះដែរ ទ្រឹស្តីនៃការផ្លាស់ប្តូរឥរិយាបថពន្យល់ថា បុគ្គលនីមួយៗប្តូរបន្តិចម្តងៗពីការយល់ដឹងទៅជាសកម្មភាព ហើយបន្ទាប់មករក្សាឥរិយាបថថ្មីៗ ដែលជាដំណើរការទាមទារឱកាសម្តងហើយម្តងទៀតសម្រាប់ការឆ្លុះបញ្ចាំង ការពិភាក្សា និងរំលឹក។[9] តាមរយៈការរៀបចំកិច្ចពិភាក្សាបុរសជាច្រើនវគ្គ អ្នកចូលរួមត្រូវបានផ្តល់ពេលវេលា និងកន្លែងដើម្បីស្រូបយកគំនិតគ្រប់គ្រាន់ និងសាកល្បងក្នុងជីវិតប្រចាំថ្ងៃ ចែករំលែកវឌ្ឍនភាពជាមួយអ្នករួមក្រុម និងទទួលបានការលើកទឹកចិត្តដើម្បីបន្តទៅមុខ។ ទាំងនេះបង្កើតបានជាវដ្តបន្តបន្ទាប់នៃការពង្រឹងការយល់ដឹងប្រឆាំងនឹងជំនឿដែលខុស និងបង្កើនអាកប្បកិរិយា និងការអនុវត្តបែបសមធម៌យេនឌ័រយូរអង្វែង។

> 📝 *សូមចំណាំថាកិច្ចពិភាក្សាបុរសប្រព្រឹត្តទៅ និងរៀបចំឡើង ដោយផ្អែកលើការពិភាក្សា ឆ្លុះបញ្ចាំង និងផ្លាស់ប្តូរមតិយោបល់ ដូចនេះវាមិនទាមទារឱ្យអ្នកចូលរួម ត្រូវតែចេះសរសេរ និងអាននោះទេ។ របៀបនៃការរៀបចំ និងសម្របសម្រួលកិច្ចពិភាក្សាបុរសអាចនឹងផ្លាស់ប្តូរទៅតាមបរិបទ ប្រភេទបញ្ហា ចំណាប់អារម្មណ៍ និងតម្រូវការរបស់អ្នកចូលរួមផ្ទាល់។*

## ៤.២ ទំហំនៃកិច្ចប្រជុំ និងអ្នកចូលរួម

ទំហំនៃកិច្ចប្រជុំមានសារៈសំខាន់ណាស់ពីព្រោះវាបានកំណត់ពីភាពងាយស្រួល ឬលំបាកសម្រាប់ការចូលរួមដោយសកម្ម និងស្មើភាពរបស់អ្នកចូលរួម។ ទំហំក្រុមដែលល្អបំផុតសម្រាប់កិច្ចពិភាក្សាបុរស គឺមានអ្នកចូលរួមពីចន្លោះពី ១៥ ទៅ ២០នាក់។ ចំនួននេះធំល្មមដើម្បីធានាបាននូវការសន្ទនាល្អ ប៉ុន្តែតូចល្មមដែលអាចឱ្យអ្នកចូលរួមនីមួយៗស្គាល់គ្នា និយាយគ្នាអំពីកង្វល់ផ្ទាល់ខ្លួនរបស់ពួកគេ និងផ្តល់មតិយោបល់ រួមទាំងមតិកែលម្អគ្រប់គ្រាន់សម្រាប់គ្នាទៅវិញទៅមក។ អ្នកចូលរួម អ្នកសម្របសម្រួល និងមានវត្តមាននៅក្នុងកិច្ច

---

[7] Ebbinghaus, H. (2013). *Memory: A contribution to experimental psychology* (H. A. Ruger & C. E. Bussenius, Trans.). Teachers College, Columbia University. (Original work published 1885).

[8] Bandura, A. (1977). *Social learning theory*. Englewood Cliffs, NJ: Prentice Hall.

[9] Prochaska, J. O., & DiClemente, C. C. (1983). Stages and processes of self-change of smoking: Toward an integrative model of change. *Journal of Consulting and Clinical Psychology, 51*(3), 390–395.

ពិភាក្សានេះត្រូវតែជាបុរសទាំងអស់។ ការដែលមានវត្តមានរបស់ស្ត្រីអាចនឹងបង្កការលំបាកទៅដល់កិច្ចពិភាក្សា ដែលប្រកបដោយសុវត្ថិភាព និងសេរីភាពសម្រាប់អ្នកចូលរួម។

ខាងក្រោមនេះជាចំណុចមួយចំនួននៃការពិចារណាសម្រាប់ការអញ្ជើញអ្នកចូលរួមឱ្យក្លាយជាផ្នែកមួយនៃក្រុមកិច្ចពិភាក្សាបុរស៖

- ប្រសិនបើក្រុមបុរសមានអ្វីដែលស្រដៀងគ្នា នោះការចែករំលែក និងពិភាក្សាអំពីរឿងរ៉ាវផ្សេងៗអាចនឹងកាន់តែងាយស្រួលសម្រាប់ពួកគេ។ ឧទាហរណ៍៖ ពួកគេមកពីតំបន់ដូចគ្នា ធ្វើការងារប្រហាក់ប្រហែលគ្នា ឬកំពុងជួបប្រទះនឹងបញ្ហាស្រដៀងគ្នាជាដើម។
- ត្រូវត្រៀមខ្លួន និងដឹងពីបញ្ហាដែលអាចកើតឡើងនៅក្នុងក្រុម ប្រសិនបើមានអ្នកចូលរួមជាក់លាក់មួយចំនួនត្រូវបានដាក់ឱ្យនៅក្នុងក្រុមជាមួយគ្នា (ឧទាហរណ៍ បុរសប្តូរយេនឌ័រ ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា អ្នកមកពីគណបក្សនយោបាយផ្សេងគ្នា សាសនាផ្សេងគ្នា ឬជាតិសាសន៍ផ្សេងគ្នា)។ ប្រសិនបើភាពខុសគ្នារវាងក្រុមទាំងនេះខ្លាំងពេក វាអាចនាំឱ្យមានអតុល្យភាពអំណាច មិនមានផាសុកភាពក្នុងការចែករំលែក ឬអាចផ្តោតលើបញ្ហាដែលមិនទាក់ទងនឹងយេនឌ័រ និងអំពើហិង្សា។ ចំពោះហេតុផលនេះ វាអាចជាការល្អក្នុងការដាក់ក្រុមជាក់លាក់ទាំងនោះនៅក្នុងកិច្ចពិភាក្សាដាច់ដោយឡែកពីគ្នាសិន បន្ទាប់ពីក្រុមទាំងនោះបានសិក្សាស្វែងយល់បានច្រើនទាក់ទងនឹងយេនឌ័រ ចម្រុះភាព ឬបរិយាបន្នហើយ ពួកគាត់នឹងបានត្រៀមខ្លួនចូលក្នុងក្រុមពិភាក្សាដែលមានបុរសគ្រប់ចម្រុះភាព។
- នៅក្នុងជំនួបលើកដំបូង អ្នកសម្របសម្រួលត្រូវលើកកម្ពស់ការពិភាក្សាអំពីគុណតម្លៃ និងការប្តេជ្ញាចិត្តដែលអ្នកចូលរួមអាចឯកភាពទាំងអស់គ្នាបាន។ ឧទាហរណ៍៖ ការមិនវាយតម្លៃគ្នា ត្រូវគោរពពេលវេលា គ្មានការរើសអើង ។ល។ លើគ្រប់មនុស្សទាំងអស់ រួមទាំងអ្នកសម្របសម្រួលដែលមានវត្តមាន។ កិច្ចព្រមព្រៀងក្នុងក្រុមទាំងនេះ គឺត្រូវចេញមកពីអ្នកចូលរួមខ្លួនឯង ហើយគួរតែត្រូវបានបង្កើតឡើង និងឯកភាពជាមួយរួមគ្នា ដូច្នេះអ្នកចូលរួមគ្រប់គ្នាមានអារម្មណ៍ថាពួកគេជាអ្នកបង្កើត និងត្រូវគោរពទាំងអស់គ្នា។

## ៤.៣ កន្លែងនៃកិច្ចប្រជុំ

កិច្ចពិភាក្សាបុរសជាកិច្ចប្រជុំដែលមានលក្ខណៈមិនផ្លូវការ ងាយស្រួល និងបរិយាបន្ន ដូច្នេះកន្លែងនៃការរៀបចំកិច្ចពិភាក្សាបុរសគួរជាទីកន្លែងបង្កលក្ខណៈងាយស្រួលដល់ការចូលរួមរបស់អ្នកចូលរួមដែលជាបុរសទាំងអស់។ ដោយហេតុថា ការរៀបចំកិច្ចពិភាក្សាបុរសមិនទាមទាឱ្យមាននូវធនធានច្រើន និង មានលក្ខណៈខុសពីការរៀន សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំផ្លូវការ ការរៀបចំទីកន្លែងសម្រាប់កិច្ចពិភាក្សាបុរសពុំចាំបាច់ត្រូវមាន តុ កៅអី ឬក្តារខៀននោះទេ។ ផ្ទុយទៅវិញ វាចាំបាច់ខ្លាំងណាស់ដែលកិច្ចប្រជុំបែបនេះត្រូវប្រព្រឹត្តិទៅនៅកន្លែងដែលមានសុវត្ថិភាពទាំងផ្លូវកាយ ផ្លូវចិត្ត និង សង្គមសម្រាប់បុរសដែលជាអ្នកចូលរួម

មកពីគ្រប់ចម្រុះភាព។ ក្នុងនោះ កន្លែងប្រជុំត្រូវមានលក្ខខណ្ឌដែលអាចឱ្យកិច្ចពិភាក្សាមានលក្ខណៈរក្សាការសំងាត់ និងភាពថ្លៃថ្នូររបស់អ្នកចូលរួមបាន។ វាអាចជាកន្លែងបិទជិត ឬឆ្ងាយដាច់ដោយឡែកពីគេ។ ជម្រើសនៃកន្លែងដែលល្អបំផុតគឺជាកន្លែងមានការចូលរួម យល់ព្រម និងជ្រើសរើសពីអ្នកចូលរួមដោយផ្ទាល់។

> 📝 *ការជ្រើសរើសទីកន្លែងសម្រាប់ជួបគ្នាគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់។ ចំណុចនេះគឺជាផ្នែកមួយនៃដំណាក់កាលធ្វើផែនការ ហើយទាមទារឱ្យមានថវិកាត្រៀមទុកជាមុន។ អ្វីដែលល្អបំផុតនោះ ទីតាំងមិនត្រូវស្ថិតនៅក្នុងសហគមន៍ដែលអ្នកចូលរួមរស់នៅនោះទេ ធ្វើដូច្នេះពួកគេនឹងមិនបានជួបមនុស្សដែលពួកគេស្គាល់ ហើយនឹងមានអារម្មណ៍មានផាសុកភាពជាងមុនក្នុងការចែករំលែកបញ្ហាផ្ទាល់ខ្លួនរបស់ពួកគេ។ អ្នកសម្របសម្រួលត្រូវទៅមើលកន្លែងមុនពេលធ្វើកិច្ចពិភាក្សាបុរសដើម្បីប្រាកដថាវាជាកន្លែងឯកជន មានផាសុកវត្ថុ ហើយនឹងមិនមានការរំខាន ឬមានបញ្ហាសុវត្ថិភាពឡើយ។ ក្នុងករណីដែលមានសមាជិកមកពីសហគមន៍នៅជិតនោះ ឬអាចមានការគំរាមកំហែងទៅកាន់ក្រុម អ្នកសម្របសម្រួលត្រូវបញ្ចប់ការប្រជុំភ្លាម ហើយផ្លាស់ទីទៅទីតាំងដែលល្អជាងនេះ។*

## ៤.៤ ពេលវេលានៃកិច្ចប្រជុំ

កិច្ចពិភាក្សាបុរសជាធម្មតាធ្វើឡើងតែរយៈពេលពី ២ម៉ោង ទៅ ៣ម៉ោង ដែលផ្អែកទៅលើទំហំនៃអ្នកចូលរួម និងការយល់ព្រមពីអ្នកចូលរួម។ ពេលវេលាជាក់លាក់នៃកិច្ចពិភាក្សាបុរសគួរត្រូវបានកំណត់ដោយអ្នកចូលរួមទៅតាមពេលដែលពួកគេអាចមកចូលរួមបាន។ គម្លាតពីកិច្ចពិភាក្សាបុរសមួយទៅកិច្ចពិភាក្សាមួយទៀតគួរតែយ៉ាងហោចណាស់ ១ ទៅ ២ខែ ដែលអាចនឹងផ្តល់ពេលវេលាគ្រប់គ្រាន់ដល់អ្នកចូលរួមនៅក្នុងការបន្តឆ្លុះបញ្ចាំង និងប្រើប្រាស់គោលគំនិត និងចំណេះដឹងដែលទទួលបានពីកិច្ចពិភាក្សាបុរសនៅក្នុងជីវភាពប្រចាំថ្ងៃ និងការអនុវត្តការងារ។

## ៤.៥ ចំនួនវគ្គ

ចំនួននៃកិច្ចពិភាក្សាបុរសគួរតែធ្វើឡើងយ៉ាងហោចណាស់ ៣ដង ក្នុងមួយឆ្នាំ។ នេះគឺជាចំនួនអប្បបរមានៃការប្រជុំ ដើម្បីធានាប្រសិទ្ធភាពរបស់កិច្ចពិភាក្សាបុរស ដែលបង្កើតកន្លែងសម្រាប់អ្នកចូលរួមមានអារម្មណ៍ធូរស្រាលជាមួយនឹងវិធីសាស្រ្ត ស្គាល់គ្នា និងមានអារម្មណ៍ជឿជាក់គ្រប់គ្រាន់ក្នុងការចែករំលែករឿងរ៉ាវផ្ទាល់ខ្លួនរបស់ពួកគេ។ ការដែលល្អបំផុត ក្រុមនីមួយៗអាចចូលរួមក្នុងការប្រជុំរហូតដល់ ៦ដង ជាមួយគ្នាក្នុងមួយឆ្នាំ។ នេះដោយសារតែបន្ទាប់ពីកិច្ចប្រជុំបន្ថែមនីមួយៗ ការរៀនសូត្រ និងការរីកចម្រើនផ្ទាល់ខ្លួនរបស់អ្នកចូលរួមនឹងមានការកើនឡើង។ បន្ទាប់ពីប្រជុំបាន ៥ ទៅ ៦ដង អ្នកចូលរួមអាចភ្ជាប់បទពិសោធន៍របស់ពួកគេទៅនឹងប្រព័ន្ធបញ្ហាយេនឌ័រ និងការរើសអើងយេនឌ័របាន។ នៅចុងបញ្ចប់នៃកិច្ចពិភាក្សាបុរសអ្នកចូលរួមត្រូវបានគេរំពឹងថានឹងទទួលបាននូវការយល់ដឹងកាន់តែស៊ីជម្រៅអំពីផ្នត់គំនិតយេនឌ័រ និងរបៀបដែលផ្នត់គំនិតទាំងនេះមានឥទ្ធិពលលើបទដ្ឋានវប្បធម៌ និងទំនាក់ទំនងអំណាច ដែលគ្រប់គ្រាន់សម្រាប់ពួកគេក្នុងការវិភាគស្ថាន

ភាពជាក់លាក់។ ពួកគេនឹងអាចកំណត់សកម្មភាពដែលខ្លួនអាចអនុវត្តបាន ដើម្បីដោះស្រាយបញ្ហា និងជំរុញឱ្យមានការផ្លាស់ប្តូរ។

តាមរយៈលទ្ធផលនៃកិច្ចពិភាក្សាបុរសនាពេលកន្លងទៅ វាមិនត្រឹមតែជាកន្លែងសុវត្ថិភាពសម្រាប់បុរសក្នុងការស្វែងយល់ពីបញ្ហាយេនឌ័រប៉ុណ្ណោះទេ ប៉ុន្តែវាបានជំរុញទឹកចិត្ត និងឱកាសដល់បុរសក្នុងការនិយាយឡើង និងក្លាយជាភ្នាក់ងារនៃការផ្លាស់ប្តូរនៅក្នុងសហគមន៍របស់ពួកគេ ដែលតួនាទី និងគោលគំនិតយេនឌ័រកម្រនឹងត្រូវបានគេលើកមកពិភាក្សា និងដោះស្រាយណាស់។ កិច្ចពិភាក្សាបុរស គឺជាចលករនៃការបំបែកភាពស្ងៀមស្ងាត់ និងជាធាតុផ្សំក្នុងការផ្លាស់ប្តូរសង្គម។ យើងសង្ឃឹមថា បន្ទាប់ពីកិច្ចកិច្ចពិភាក្សាបុរសដែលបានរៀបចំជាបន្តបន្ទាប់មក អ្នកចូលរួមនឹងបន្តការប្រជុំរបស់ពួកគេដោយខ្លួនឯងទៅតាមបរិបទក្នុងសហគមន៍រៀងៗខ្លួន។

## ៤.៦ ការកំណត់ និងរៀបចំប្រធានបទ

ធាតុផ្សំសំខាន់នៃកិច្ចពិភាក្សាបុរស គឺថាការប្រជុំនីមួយៗនិយាយអំពីប្រធានបទសំខាន់មួយ ដែលប្រធានបទនោះមានសារៈសំខាន់ចំពោះអ្នកចូលរួម។

👇 ខាងក្រោមគឺជាឧទាហរណ៍មួយចំនួននៃប្រធានបទគំរូដែលអ្នកសម្របស្រួលអាចធ្វើការពិចារណា និងដាក់បញ្ចូលទៅក្នុងបរិបទផ្សេងៗទៅតាមតម្រូវការ៖

- ភាពជាបុរសបែបវិជ្ជមាន និងអវិជ្ជមាន
- អំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ
- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិដែលមានស្រាប់ ដែលពាក់ព័ន្ធនឹងការចូលរួមរបស់បុរស ព្រមទាំងការគាំទ្រ និងការពារស្ត្រី
- សមភាព និងសមធម៌យេនឌ័រ
- តួនាទីយេនឌ័រ
- ប្រព័ន្ធបិតាធិបតេយ្យ
- សិទ្ធិផ្លូវភេទ និងសិទ្ធិសុខភាពបន្តពូជ
- អន្តរប្រសព្វ
- ការចិញ្ចឹមកូនបែបវិជ្ជមាន
- ការរើសអើង និងសិទ្ធិជនមានពិការភាព និងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា
- ការបៀតបៀនផ្លូវភេទ...។

វាមានសារៈសំខាន់ណាស់ក្នុងការដែលអ្នកសម្របសម្រួលបានរៀបចំខ្លួនឱ្យបានរួចរាល់ដើម្បីពិភាក្សាអំពីប្រធានបទដែលបានជ្រើសរើសទុកមុន។ នៅមុនពេលប្រជុំ អ្នកសម្របសម្រួលត្រូវប្រមូលព័ត៌មាន និងបង្កើតកម្រងសំណួរសម្រាប់ការឆ្លុះបញ្ចាំង។ ឧទាហរណ៍ អ្នកសម្របសម្រួលអាច៖

- ស្វែងរកសាច់រឿង និងករណីសិក្សាទាក់ទងទៅនឹងប្រធានបទដែលបានជ្រើសរើស។ វាមានសារៈសំខាន់ណាស់ក្នុងការមានឧទាហរណ៍ខ្លះនៃរឿងរ៉ាវផ្ទាល់ខ្លួនរបស់មនុស្សដែលទាក់ទងនឹងប្រធាន

បទនេះ ពីព្រោះកិច្ចពិភាក្សាបុរសសំខាន់គឺនិយាយអំពីបទពិសោធន៍ផ្ទាល់ខ្លួន។ ឧទាហរណ៍៖ អ្នកសម្របសម្រួលអាចចែករំលែករឿងអនាមិកមួយ ដើម្បីលើកទឹកចិត្តអ្នកចូលរួមឱ្យបើកចំហរ និងនិយាយអំពីបញ្ហានោះ។ នៅពេលចែករំលែកតាមរបៀបទូទៅនេះ អ្នកចូលរួមមិនចាំបាច់និយាយអំពីបទពិសោធន៍ផ្ទាល់ខ្លួនទេ ប្រសិនបើពួកគេមិនទាន់បានត្រៀមខ្លួនរួចរាល់។

- ស្វែងរកព័ត៌មានអំពីច្បាប់ឬគោលនយោបាយណាមួយដែលពាក់ព័ន្ធទៅនឹងប្រធានបទ។ ឧទាហរណ៍៖ ក្នុងអំឡុងពេលប្រជុំមួយ នៅពេលដែលមានករណីអំពើហិង្សាលើស្ត្រី និងក្មេងស្រីបានលើកឡើង អ្នកសម្របសម្រួលអាចសួរអ្នកចូលរួមដោយផ្ទាល់ថា តើពួកគេដឹងពីគោលនយោបាយឬច្បាប់ណាដែលពាក់ព័ន្ធទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដែរឬទេ។ បើមិនមានអ្នកណាដឹងទេ វាគួរតែជាប្រធានបទសម្រាប់ការពិភាក្សានៅក្នុងកិច្ចពិភាក្សាបុរសបន្ទាប់។

## កិច្ចប្រជុំលើកទីមួយ

នៅក្នុងកិច្ចប្រជុំលើកទីមួយនៃកិច្ចពិភាក្សាបុរស គោលដៅសំខាន់បំផុតគឺជាការណែនាំឱ្យអ្នកចូលរួមបានយល់ពីដំណើរការ និងគោលបំណងរបស់កិច្ចពិភាក្សាបុរសទាំងមូល ព្រមទាំងការយល់ព្រមទៅលើគោលការណ៍មួយចំនួនដែលជាកិច្ចព្រមព្រៀងរបស់ក្រុម។ ក្នុងនោះដែរ សម្រាប់កិច្ចប្រជុំដំបូងនេះអ្នកសម្របសម្របសម្រួលត្រូវព្យាយាមបង្កើតឱ្យមានបរិយាកាសដែលអាចនាំឱ្យអ្នកចូលរួមបានស្គាល់គ្នា និងបង្កើតនូវទំនុកចិត្តចំពោះគ្នាទៅវិញទៅមក។ នេះអាចធ្វើឡើងតាមរយៈការណែនាំខ្លួន និងព័ត៌មានផ្ទាល់ខ្លួនមួយចំនួនដែលអ្នកចូលរួមមានអារម្មណ៍សុវត្ថិភាពនៅក្នុងការចែករំលែក។ បន្ទាប់មកកិច្ចប្រជុំអាចបន្តជាមួយនឹងការពិភាក្សាទៅលើបញ្ហាភាពជាបុរស និង យេនឌ័រ។ ជាទូទៅអ្នកសម្របសម្រួលអាចចាប់ផ្តើមពីការសួរសំនួរពីស្ថានភាពរបស់អ្នកចូលរួម តួនាទីយេនឌ័រ និងបញ្ហាយេនឌ័រ (វិសមភាព) បញ្ហាភាពជាបុរស នៅកន្លែងការងារជាដើម។ ព័ត៌មានទូទៅនៃបញ្ហាយេនឌ័រទាំងនេះនឹងអាចជួយឱ្យអ្នកសម្របសម្រួលកំណត់បាននូវប្រធានបទចម្បងៗ សម្រាប់ការពិភាក្សាលើកក្រោយទៀត។

## កិច្ចប្រជុំលើកទីពីរ និងកិច្ចប្រជុំបន្តបន្ទាប់ទៀត

នៅចុងបញ្ចប់នៃកិច្ចប្រជុំនីមួយៗ អ្នកសម្របសម្រួលគួរបញ្ចប់ និងសង្ខេបនូវអ្វីដែលបានពិភាក្សា ជាការយល់ដឹង និងការឆ្លុះបញ្ចាំងយ៉ាងសំខាន់ ក្នុងចំណោមអ្នកចូលរួមទាំងអស់។ បន្ទាប់មក អ្នកសម្របសម្រួលគួរពិភាក្សាអំពីគំនិតផ្សេងៗសម្រាប់ប្រធានបទបន្ទាប់ជាមួយក្រុម ហើយធ្វើការសម្រេចចិត្តរួមគ្នា។ វាក៏អាចអាស្រ័យលើវឌ្ឍនភាពដែលបានកើតឡើងនៅក្នុងកិច្ចប្រជុំផងដែរ។ ពេលខ្លះ ក្រុមទាំងមូលអាចមិនបញ្ចប់ការពិភាក្សាអំពីប្រធានបទដែលបានរៀបចំ ហើយប្រហែលជាចង់បន្តពិភាក្សាអំពីប្រធានបទដដែលនោះនៅក្នុងកិច្ចប្រជុំបន្ទាប់ក៏ថាបាន។ ជួនកាលទៀត ប្រធានបទមួយ អាចត្រូវចំណាយពេលប្រជុំបីដង ដើម្បីឱ្យការពិភាក្សាបានត្រឹមត្រូវ និងច្បាស់លាស់។ ប្រសិនបើក្រុមយល់ថាពួកគេបានបញ្ចប់ប្រធានបទនោះហើយ ពួកគេអាចស្នើ (និងយល់ព្រម) លើប្រធានបទសម្រាប់កិច្ចប្រជុំបន្ទាប់។

## ៤.៧ ការបង្កើតកម្រងសំណួរដើម្បីធ្វើការឆ្លុះបញ្ចាំង

ដើម្បីសម្របសម្រួលការជជែកនៅក្នុងកិច្ចពិភាក្សាបុរសឱ្យមានភាពរលូន អ្នកសម្របសម្រួលត្រូវបានលើកទឹកចិត្តឱ្យរៀបចំកម្រងសំណួរទាក់ទងនឹងប្រធានបទដែលបានជ្រើសរើសទុកជាមុន។ សំណួរទាំងនេះនឹងជួយជំរុញឱ្យមានការចែករំលែកបទពិសោធន៍ និងការពិភាក្សា។ សំណួរបីប្រភេទផ្សេងគ្នាអាចជា៖

### ក. សំណួរដើម្បីជំរុញឱ្យអ្នកចូលរួមនិយាយ

ជាដំបូង សំណួរគួរតែជាសំណួរបើកដើម្បីផ្តល់ឱកាសដល់អ្នកចូលរួមប្រាប់រឿងដែលពួកគេចង់ធ្វើការចែករំលែក។ ប្រសិនបើមើលទៅដូចជាមានការលំបាកសម្រាប់អ្នកចូលរួមក្នុងការនិយាយចេញមក អ្នកសម្របសម្រួលអាចធ្វើការចែករំលែកជាមុនសិន។ គាត់អាចធ្វើការចែករំលែកអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ ឬលើកអំពីករណីសិក្សាណាមួយ ប៉ុន្តែត្រូវចាំថាវាជាការនិយាយចេញពីទស្សនៈផ្ទាល់ខ្លួនរបស់គាត់។ ជាទូទៅអ្នកចូលរួមនឹងចាប់ផ្តើមនិយាយអំពីប្រធានបទមួយក្នុងន័យទូទៅ អ្នកសម្របសម្រួលគួរសួរសំណួរប្រដេញដើម្បីជំរុញពួកគេឱ្យប្រាប់អំពីបទពិសោធន៍ និងទស្សនៈផ្ទាល់ខ្លួនរបស់ពួកគេ ឬបទពិសោធន៍ណាមួយរបស់បុរសផ្សេងទៀតដែលពួកគេស្គាល់បានជួបប្រទះ។

### ខ. សំណួរដើម្បីវិភាគស្ថានភាព និងភ្ជាប់ទៅនឹងបញ្ហាយេនឌ័រ

សំណួរនោះគួរតែនាំអ្នកចូលរួមឱ្យគិតអំពីមូលហេតុជាមូលដ្ឋាន។ សំណួរសំខាន់មួយគឺ៖ ហេតុអ្វី? ហេតុអ្វីបានជាមនុស្សប្រព្រឹត្តបែបនោះ? ហេតុអ្វីបានជាពួកគេគិតថាវាត្រឹមត្រូវ ឬខុស? តើអ្នកគិតថា អាកប្បកិរិយាបែបនេះយុត្តិធម៌ចំពោះស្ត្រី និងក្មេងស្រីដែរឬទេ?

### គ. សំណួរដើម្បីបង្កើតសកម្មភាព

ជាតុសំខាន់មួយនៅក្នុងកិច្ចពិភាក្សាបុរស គឺការចែករំលែកបទពិសោធន៍ និងស្វែងយល់ពីស្ថានភាព ប៉ុន្តែអ្វីដែលសំខាន់បំផុតនោះ គឺត្រូវកំណត់នូវអ្វីដែលយើងអាចធ្វើបានដើម្បីបង្កើតឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន និងជាពិសេសការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។ សំណួរទាំងនោះគួរតែធ្វើឱ្យអ្នកចូលរួមអាចកំណត់សកម្មភាពជាក់ស្តែងផ្សេងៗដែលពួកគេអាចធ្វើបាននៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ តើចង់ឱ្យស្ថានភាពនោះនៅដដែលទេ? តើចង់ផ្លាស់ប្តូរទេ? តើអាចធ្វើអ្វីដោយខ្លួនឯង ឬជាមួយអ្នកដទៃ ដើម្បីធ្វើឱ្យស្ថានការណ៍កាន់តែប្រសើរឡើងទេ? តើអាចធ្វើអ្វីខ្លះដើម្បីឱ្យវាកើតឡើង ឬ ដោះស្រាយបញ្ហានេះបាន?

សំណួររបស់អ្នកសម្របសម្រួលនឹងជួយអ្នកចូលរួមក្នុងការកំណត់ និងស្វែងយល់អំពីវិសមភាពយេនឌ័រនៅក្នុងសង្គម។ ដូច្នេះ អ្នកសម្របសម្រួលគួរតែចងចាំបញ្ហាខាងក្រោមនៅពេលណែនាំការពិភាក្សា៖

- តម្រូវការ តួនាទី និងផលប្រយោជន៍ផ្សេងៗគ្នារបស់ស្ត្រី និងបុរសនៅក្នុងសហគមន៍
- ទំនាក់ទំនងរវាងស្ត្រី និងបុរស ទាក់ទងនឹងការទទួលបាន និងការគ្រប់គ្រងធនធាន និងសេវាកម្ម

- វិសមភាពអំណាចរវាងបុរស និងស្ត្រីអាចប៉ះពាល់សិទ្ធិស្ត្រី និងគាំទ្រអំពើហិង្សាតាមរយៈការបង្ហាញអំពីភាពត្រឹមត្រូវនៃការប្រើប្រាស់អំពើហិង្សា
- ឧបសគ្គខាងផ្នែកសង្គម វប្បធម៌ និងរចនាសម្ព័ន្ធ និងឱកាសសម្រាប់ស្ត្រី និងបុរស។

## ៥. វិធីសាស្ត្រសម្របសម្រួលបែបហ្វេមមីនីស្ត

ដើម្បីចាប់ផ្តើមកិច្ចពិភាក្សាបុរស និងដើម្បីឱ្យការប្រជុំទទួលបានជោគជ័យ អាកប្បកិរិយា និងជំនាញផ្សេងៗដ៏ប៉ិនប្រសប់របស់អ្នកសម្របសម្រួលគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់។ ជំហានបន្ទាប់នេះនឹងសង្ខេបអំពីចំណុចសំខាន់ៗរបស់អ្នកសម្របសម្រួលបែបហ្វេមមីនីស្ត ដែលនឹងអាចមានប្រយោជន៍សម្រាប់ការជ្រើសរើសការបណ្តុះបណ្តាល និងការណែនាំ។ មុនពេលចាប់ផ្តើមអ្នកសម្របសម្រួលទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងការបណ្តុះបណ្តាលកសាងសមត្ថភាពស្តីអំពីយេនឌ័រ អំពើហិង្សា ការរើសអើង ការទំនាក់ទំនងប្រកបដោយបរិយាបន្ន និងឱកាសផ្សេងទៀតសម្រាប់ការរៀនសូត្រដែលពាក់ព័ន្ធនឹងការចូលរួមរបស់បុរសក្នុងការពិភាក្សាប្រកបដោយប្រសិទ្ធិភាព។ អ្នកសម្របសម្រួលកិច្ចពិភាក្សាបុរសគួរតែៈ

- ❖ រៀបចំខ្លួនឱ្យបានរួចជាស្រេច ហើយជឿជាក់លើខ្លួនឯង

អ្នកសម្របសម្រួលត្រូវរៀបចំទុកជាមុនអំពីប្រធានបទដែលចង់ពិភាក្សា ហើយក៏ត្រូវមានចំណេះដឹងបន្ថែមលើប្រធានបទនោះផងដែរ។ នេះមិនមែនមានន័យថា អ្នកសម្របសម្រួលត្រូវតែដឹងរាល់អ្វីៗទាំងអស់នោះទេ ប៉ុន្តែគាត់ត្រូវតែជឿថា មនុស្សគ្រប់រូបមានចំណេះដឹងដែលមនុស្សផ្សេងទៀតអាចរៀនសូត្រពីគ្នាបានទៅវិញទៅមក ធ្វើដូច្នេះការប្រជុំគឺជាដំណើរការនៃការរៀនសូត្រ។

- ❖ លើកទឹកចិត្តឱ្យមានការពិភាក្សា

ទោះបីជាអ្នកសម្របសម្រួលមានចំណេះដឹងជាក់លាក់ទាក់ទងទៅនឹងយេនឌ័រក៏ដោយ អ្នកសម្របសម្រួល គួរតែទប់សិនមុននឹងធ្វើការឆ្លើយតបដោយផ្ទាល់ទៅនឹងសំណួរនោះទេ។ នៅពេលដែលមានសំណួរលើកឡើង វាជាការសំខាន់ណាស់ក្នុងការផ្តល់សំណួរនោះត្រឡប់ទៅឱ្យក្រុមដើម្បីធ្វើការពិភាក្សាវិញ។ បំបែកសំណួរទៅជាសំណួរតូចៗ ដើម្បីដឹកនាំការគិត និងការវិភាគរបស់អ្នកចូលរួម។

- ❖ កុំធ្វើការវិនិច្ឆ័យ

នៅក្នុងកិច្ចពិភាក្សាបុរស ភាពស្មើគ្នាមានសារៈសំខាន់ណាស់។ អ្នកចូលរួមគ្រប់រូបមានគុណតម្លៃ ហើយអ្វីដែលពួកគេនិយាយគឺសំខាន់។ យកបញ្ហា សំណួរ ការសង្កេត ត្រឡប់មកដាក់ក្នុងក្រុមវិញដើម្បីធ្វើការពិភាក្សា ប៉ុន្តែកុំធ្វើការវិនិច្ឆ័យអំពីថាតើវាត្រូវ ឬខុស។ វាក៏សំខាន់ផងដែរក្នុងការធ្វើឱ្យប្រាកដថាអ្នកចូលរួមមិនវិនិច្ឆ័យគ្នាទៅវិញទៅមក។ មនុស្សគ្រប់រូបត្រូវតែមានតម្លៃស្មើៗគ្នា។

- ❖ ផ្តល់ឱកាសដល់អ្នកចូលរួមគ្រប់ៗគ្នា

អ្នកចូលរួមគ្រប់រូបគួរតែមានឱកាសក្នុងការនិយាយទោះបីជាពួកគេមានការអៀនខ្មាសក៏ដោយ។

ឧទាហរណ៍៖ ប្រសិនបើអ្នកចូលរួមនិយាយថា "ខ្ញុំយល់ស្របនឹងអ្វីដែលបាននិយាយ" បន្ទាប់មកត្រូវជំរុញពួកគេឱ្យនិយាយបន្ថែមទៀតអំពីបញ្ហានោះ។ ត្រូវសួរសំណួរដូចជា៖ តើអ្នកយល់ស្របជាមួយអ្វី? ប្រាប់យើងបន្ថែមអំពីគំនិតរបស់អ្នកបានទេ? តើបទពិសោធន៍របស់អ្នកដូចម្តេចដែរ?

❖ លើកទឹកចិត្តអ្នកដែលនៅស្ងៀមឱ្យនិយាយ

ឱ្យអ្នកដែលនិយាយច្រើនទុកកន្លែងសម្រាប់អ្នកដទៃផង។ ស្នើឱ្យមានការសហការសម្របសម្រួលចេញពីក្នុងក្រុម!

❖ មានការយល់ដឹងល្អអំពីទិដ្ឋភាព និងបញ្ហាយេនឌ័រ

ដើម្បីអាចធ្វើការណែនាំអ្នកចូលរួមឱ្យផ្សារភ្ជាប់បទពិសោធន៍របស់ពួកគេទៅនឹងបញ្ហាទាក់ទងនឹងយេនឌ័រ និងមូលហេតុ ឫសគល់របស់ពួកគេ ដូចជាផ្នត់គំនិតយេនឌ័រ តួនាទីយេនឌ័រ និងការបែងចែកការងារ បទដ្ឋាននៃវប្បធម៌ និងទំនាក់ទំនងអំណាច - អ្នកសម្របសម្រួលត្រូវតែមានចំណេះដឹងអំពីបញ្ហាទាំងនេះ។

❖ ត្រូវរៀបចំឱ្យបានល្អអំពីប្រធានបទ

ដោយសារតម្រូវការរបស់ក្រុមកំពុងតែរីកធំឡើង ការប្រជុំខ្លះអាចមានការផ្តោតលើប្រធានបទដែលអ្នកសម្របសម្រួលមិនសូវស្គាល់ច្បាស់។ ក្នុងករណីនេះ អ្នកសម្របសម្រួលត្រូវប្រមូលព័ត៌មាន និងសិក្សាអំពីប្រធានបទឱ្យបានច្រើន។

❖ ត្រូវមានភាពបត់បែន

តម្រូវការរបស់ក្រុមត្រូវជារឿងអាទិភាព។ បើទោះបីជាមានសេចក្តីណែនាំ និងមានផែនការវគ្គជាឧទាហរណ៍ក៏ដោយ ពេលខ្លះអ្នកសម្របសម្រួលត្រូវផ្លាស់ប្តូរផែនការទៅតាមអ្វីដែលកំពុងតែកើតមានឡើងនៅក្នុងក្រុម។ ទទួលយកនូវអ្វីដែលក្រុមត្រូវការ ហើយរៀបចំប្រធានបទ និងកម្រងសំណួរទៅតាមនោះ។ ទោះបីជាមានប្រធានបទដែលមិននឹកស្មានដល់កើតឡើងក៏ដោយ ត្រូវមានភាពបត់បែនក្នុងការផ្លាស់ប្តូរទៅរកប្រធានបទនេះ ប្រសិនបើវាមានសារៈសំខាន់ចំពោះអ្នកចូលរួម។ ប្រសិនបើប្រធានបទនោះវាថ្មីពេកសម្រាប់អ្នកសម្របសម្រួល គាត់អាចយកវាមកកាន់ក្រុមវិញបាន ដើម្បីរកមើលថាតើពួកគេចង់រៀនអំពីអ្វី ហើយរៀបចំព័ត៌មានបន្ថែមអំពីរឿងនេះសម្រាប់វគ្គក្រោយ។

❖ ផ្តោតសំខាន់ទៅលើអំណាចខាងក្នុង

ត្រូវមានឆន្ទៈក្នុងការពង្រឹងអំណាចជាមួយរបស់អ្នកឱ្យកាន់តែស៊ីជម្រៅនៅក្នុងខ្លួន ហើយមិនបំពាន "អំណាចលប់លើ" ក្នុងនាមជាអ្នកសម្របសម្រួល ហើយត្រូវនិយាយដោយក្លាហានប្រឆាំងនឹងភាពអយុត្តិធម៌ដែលកើតឡើង។ ត្រៀមខ្លួនឱ្យបានរួចរាល់ដើម្បីទប់អារម្មណ៍ពិបាក ធ្វើការបិទវគ្គដោយមានការបញ្ចូលសារសម្រាប់ក្រុមគោលដៅយកទៅផ្ទះបញ្ចាំង ... បញ្ចប់ដោយកំណត់ចំណាំខ្ពស់!

❖ ធ្វើការកោតសរសើរ និងជំហានបន្ទាប់

ទុកឱកាសឱ្យអ្នកចូលរួមចែករំលែកគំនិតផ្ទាល់ខ្លួនរបស់ពួកគេអំពីកិច្ចពិភាក្សាបុរស និងបង្កើតជាគំនិតអំពីអ្វីដែលពួកគេចង់ពិភាក្សានៅវគ្គបន្ទាប់។ ពេលវេលាប្រជុំ វេទិកានៃកិច្ចប្រជុំ និងប្រធានបទ នឹងត្រូវសម្រេច និងយល់ព្រមដោយអ្នកចូលរួម។ ជាចុងក្រោយ អបអរសាទរ និងកោតសរសើរចំពោះការចូលរួមរបស់ពួកគាត់។

## ៦. ការប្រុងប្រយ័ត្ននៅពេលពិភាក្សាអំពីភាពជាបុរស និងហ្វេមមីនីស្ត

នៅពេលធ្វើការជាមួយបុរស ទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ពីរបៀបក្នុងការជជែកពិភាក្សាទាក់ទងនឹងភាពជាបុរសដែលអវិជ្ជមាន។ ប្រសិនបើមិនបានប្រុងប្រយ័ត្នទេ កិច្ចពិភាក្សាទាំងនេះអាចនឹងបានត្រឹមតែជាការជជែក និងនាំឱ្យមានការកេងចំណេញផលប្រយោជន៍បន្ថែមទៀត (tokenism) ដែលបុរសខ្លះគ្រាន់តែបង្ហាញការគាំទ្រដល់សមភាពយេនឌ័រ ដោយមិនបានយល់ច្បាស់ ឬអនុវត្តនៅក្នុងជីវិតពិតជាក់ស្តែងរបស់ខ្លួនឡើយ។ ម្យ៉ាងវិញទៀត វាជារឿងសំខាន់ដែលអ្នកសម្របសម្រួលត្រូវចងចាំថាប្រទេសកម្ពុជាគឺជាសង្គមបែបបិតាធិបតេយ្យមួយ។ បុរសមួយចំនួនបន្តទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធនេះ ហើយពួកគេគ្រាន់តែចូលរួមជាមួយការងារទាក់ទងនឹងសមភាពយេនឌ័រនៅក្នុងកម្រិតមួយស្តួចស្តើងតែប៉ុណ្ណោះ។
ហេតុនេះហើយ ការផ្សារភ្ជាប់គុណតម្លៃហ្វេមមីនីស្តគឺមានសារៈសំខាន់ក្នុងការទប់ស្កាត់បុរសពីការគ្រប់គ្រងនូវលំហ ឬវេទិការបស់ស្ត្រី មុនពេលពួកគេបានផ្លាស់ប្រែខ្លួនឯងពិតប្រាកដ សូម្បីតែពួកគេធ្លាប់ទទួលបានវគ្គនៃការបណ្តុះបណ្តាលកសាងសមត្ថភាពមួយចំនួនរួចហើយក៏ដោយ។ វាទាមទារឱ្យមានការបញ្ជាក់ច្បាស់លាស់ពីនិយមន័យ និងគោលដៅនៃសមភាពយេនឌ័រ និងហ្វេមមីនីស្ត ដែលមិនមែនដើម្បីផាត់បុរស ឬស្ត្រី ឬអ្នកមានអត្តសញ្ញាណចម្រុះផ្សេងទៀតចេញឡើយ ឬក៏លើកកម្ពស់ក្រុមណាមួយដើម្បីគាបសង្កត់ក្រុមណាមួយនោះទេ ប៉ុន្តែគឺជាការបង្កើតនូវបរិយាកាសសម្រាប់គ្រប់គ្នាប្រកបដោយសមភាព ការគាំទ្រ និងគោរពគ្នាប្រកបដោយសេចក្តីថ្លៃថ្នូរ។ ទាំងនេះជាមូលដ្ឋានគ្រឹះ ដែលធានាថាបុរសបានយល់កាន់តែច្បាស់អំពីគោលដៅចុងក្រោយដែលហ្វេមមីនីស្តចង់បាន និងការពារពីការអះអាងថាពួកគេជាបុគ្គលហ្វេមមីនីស្ត ឬពួកគេបានផ្លាស់ប្តូរ ខណៈដែលសកម្មភាព និងអាកប្បកិរិយារបស់ខ្លួននៅតែឆ្លុះបញ្ចាំងពីការបង្កគ្រោះថ្នាក់ដដែល។

## ៧. ការសម្របសម្រួលកិច្ចពិភាក្សាបុរសតាមប្រព័ន្ធអនឡាញ

នៅក្នុងអំឡុងឆ្នាំ២០២០ អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) បានណែនាំការកែសម្រួលកិច្ចពិភាក្សាបុរសទៅជាទម្រង់តាមប្រព័ន្ធអនឡាញ។ ការមានកន្លែងដើម្បីពិភាក្សា ចែករំលែកបញ្ហា និងដំណោះស្រាយក្នុងអំឡុងពេលការរាតត្បាតជំងឺកូវីដ-១៩ គឺពិតជាមានការលំបាកខ្លាំងណាស់ ជាពិសេសអ្នកដែលរស់នៅតាមសហគមន៍ជនបទ។

ជំងឺកូវីដ-១៩ បានរឹតត្បិតពេលវេលាបន្ថែមទៀតទៅលើស្ត្រី និងក្មេងស្រីដោយសារតែពួកគេត្រូវបានសង្គមដាក់ទំនួលខុសត្រូវលើការងារថែទាំដែលមិនមានប្រាក់កម្រៃកាន់តែច្រើនជាងមុនលើកិច្ចការងារផ្ទះ បើធៀបទៅនឹងបុរស និងក្មេងប្រុស។ បញ្ហាកំណើននៃអំពើហិង្សាក្នុងគ្រួសារក៏កើតមានឡើងនៅក្នុងអំឡុងពេលនោះផងដែរ។ ដោយសង្កេតឃើញនូវបញ្ហាទាំងនេះ អង្គការ GADC បានឆ្លើយតបតាមរយៈការកែសម្រួលកិច្ចពិភាក្សាបុរសទៅជាសកម្មភាពតាមប្រព័ន្ធអនឡាញ។

វេទិកាអនឡាញដែលត្រូវបានជ្រើសរើសសម្រាប់បុរស គួរតែជាកម្មវិធីបណ្តាញសង្គមមួយដែលអ្នកចូលរួមបានស្គាល់រួចមកហើយដូចជា កម្មវិធីអេប ហ្វេសប៊ុក (Facebook) មេសិនជើ (Messenger) ឡាញ (Line)

តេលេក្រាម (Telegram) ហ៊្សូម (Zoom) ស្កៃប (Skype) ម៉ាយក្រូសូហ្វ ធីម (Microsoft Teams) ជាដើម។ វាអនុញ្ញាតឱ្យអ្នកចូលរួមងាយស្រួលចូលប្រើ និង/ឬ ប្រើប្រាស់កម្មវិធី និងដើម្បីធានាថាពួកគេមានអារម្មណ៍កាន់តែមានទំនុកចិត្ត និងផាសុកភាព។ ក្នុងពេលកិច្ចប្រជុំលើកដំបូង អ្នកសម្របសម្រួលត្រូវពិភាក្សាអំពីសុវត្ថិភាពអនឡាញ (Cyber Safety) ដើម្បីធានាថាអ្នកចូលរួមដឹងអំពីបញ្ហានានាទាក់ទងទៅនឹងសុវត្ថិភាពអនឡាញ និងវិធីការពារឯកជនភាពរបស់ពួកគេ (ការប្រើប្រាស់សារជាសំឡេង/វីដេអូ ប្រសិនបើមានការសរសេរសារក្នុងប្រអប់ជជែក ត្រូវប្រាកដថាសារទាំងនោះនឹងត្រូវបានលុបចេញវិញនៅពេលក្រោយ ។ល។) ។

ប្រសិនបើនរណាម្នាក់ចែករំលែកថា ពួកគេ ឬអ្នកក្នុងសហគមន៍ដែលពួកគេស្គាល់ដទៃទៀតកំពុងជួបប្រទះអំពើហិង្សា នៅក្នុងកិច្ចពិភាក្សាបុរសដែលរៀបចំឡើងតាមប្រព័ន្ធអនឡាញនឹងមានភាពស្មុគស្មាញជាងមុនទាក់ទងនឹងការធានាអំពីការបញ្ជូនអ្នកទាំងនោះទៅរកភ្នាក់ងារដែលនៅជិត។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកសម្របសម្រួលត្រូវតែមានបញ្ជីអ្នកផ្តល់សេវាដែលនៅជិតបំផុត (ឬលេខទូរស័ព្ទទាន់ហេតុការណ៍) ហើយអាចស្នើសុំឱ្យអ្នកចូលរួមបន្តនៅក្នុងកម្មវិធី បន្ទាប់ពីក្រុមទាំងមូលបានចាកចេញ។ នៅក្នុងពេលដែលមានតែពីរនាក់បែបនេះ អ្នកសម្របសម្រួលអាចផ្តល់ការគាំទ្រផ្នែកអារម្មណ៍ បញ្ជាក់ពីបទពិសោធន៍របស់ពួកគេ និងទាមទារឱ្យមានការផ្តល់ព័ត៌មានអំពីការគាំទ្រផ្សេងៗទៀត។

# ៨. គោលការណ៍ និងក្រមសីលធម៌របស់អ្នកសម្របសម្រួល

## ៨.១ ទំនួលខុសត្រូវផ្នែកសីលធម៌

កិច្ចពិភាក្សាបុរស គឺនិយាយអំពីបទពិសោធន៍ផ្ទាល់ខ្លួន ហើយជាធម្មតា មានប្រធានបទខ្លះដែលបុរសមិនធ្លាប់បាននិយាយជាមួយអ្នកដទៃ។ វាជាការសំខាន់ណាស់ដែលត្រូវប្រាកដថាអ្នកចូលរួមមានអារម្មណ៍ផាសុកភាព សុវត្ថិភាព ការគោរព និងមិនមានការរើសអើងលើអ្នកមានអត្តសញ្ញាណយេនឌ័រណាទាំងអស់។ អ្នកចូលរួមមិនត្រូវទទួលរងសម្ពាធណាមួយដើម្បីចូលរួមក្នុងការពិភាក្សានោះទេ។ ការចូលរួមគឺត្រូវតែធ្វើឡើងដោយការស្ម័គ្រចិត្ត។ អ្នកសម្របសម្រួលត្រូវធានាថាអ្នកចូលរួមមកពីក្រុមផ្សេងគ្នា អាចមានស្ថានភាពផ្សេងគ្នា ហើយត្រូវអនុញ្ញាតឱ្យអ្នកចូលរួមបោះឆ្នោតជ្រើសរើសពេលវេលា និងកាលបរិច្ឆេទដែលល្អបំផុតសម្រាប់ពួកគេដើម្បីជួបគ្នាគឺជាអាទិភាពមួយ ដើម្បីឱ្យប្រាកដថាពួកគេអាចចូលរួមបាន ហើយមិនខកខានការប្រជុំណាមួយដោយសារតែសកម្មភាពប្រចាំថ្ងៃ ឬកាលវិភាគដ៏មមាញឹករបស់ពួកគេនោះទេ។

## ៨.២ ការគ្រប់គ្រងព័ត៌មានរសើប

ក្នុងអំឡុងពេលកិច្ចប្រជុំកិច្ចពិភាក្សាបុរស ប្រធានបទខ្លះអាចធ្វើឱ្យអ្នកចូលរួមមានភាពងាយរងឥទ្ធិពលផ្នែកអារម្មណ៍ ឬមានការប៉ះទង្គិចផ្លូវចិត្ត ក្នុងករណីដែលមានអ្នកចូលរួម ចែករំលែកថាពួកគេកំពុងនៅក្នុងស្ថាន

ភាពណាមួយនៃអំពើហិង្សា ឬ ប្រព្រឹត្តអំពើហិង្សា អ្នកសម្របសម្រួលត្រូវប្រុងប្រយ័ត្ន និងមាននីតិវិធីច្បាស់លាស់សម្រាប់ការជជែកពិភាក្សា។

ករណីអ្នកចូលរួមស្ថិតនៅក្នុងការរងគ្រោះនៃអំពើហិង្សា ដើម្បីការពារសុវត្ថិភាព និងសុខុមាលភាពរបស់ពួកគេ អ្នកសម្របសម្រួលត្រូវត្រៀមខ្លួនជាមុន ដោយណែនាំពួកគេទៅកាន់ស្ថាប័ន ឬភ្នាក់ងារដែលនៅជិតបំផុត ហើយអាចផ្តល់ជំនួយបានភ្លាមៗ។ មុនពេលធ្វើការបញ្ជូន ឬរាយការណ៍ យើងត្រូវសុំការយល់ព្រមពីសាមីខ្លួនជាមុន។ ទោះជាយ៉ាងណា អ្នកសម្របសម្រួលគួរតែស្គាល់ និងយល់អំពីក្របខ័ណ្ឌច្បាប់ សម្រាប់ករណីដែលចាំបាច់ត្រូវធ្វើការរាយការណ៍តាមផ្លូវច្បាប់។ ថ្លៃដំណើរទៅកាន់សេវាបន្ទាន់ និងថ្លៃសេវាផ្សេងៗដែលទាក់ទងនឹងការផ្តល់ជំនួយទាំងនេះ គួរតែត្រូវបានបញ្ចូលក្នុងថវិកាគម្រោងជាមុនផងដែរ។

**ស្ថាប័ន ឬភ្នាក់ងារមួយចំនួនដែលផ្តល់ជំនួយបន្ទាន់៖**

- នគរបាល៖ ១១៧
- នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនក្រសួងមហាផ្ទៃ៖ ១២៨៨
- រថយន្តសង្គ្រោះបន្ទាន់ ឬជំនួយសុខាភិបាល៖ ១១៩
- បណ្តាញទូរសព្ទជំនួយ និងពិគ្រោះយោបល់៖ ១២៨០
- ក្រសួងកិច្ចការនារី៖ ០៩៣៧៧៧៩០០ ឬ ០៨៥៧៧៧៩០០
- ការគាំទ្រផ្នែកផ្លូវចិត្ត និងសង្គម៖ ០១៧២២២៣៧២

*សម្គាល់៖ បណ្តាញទំនាក់ទំនងអាចនឹងមានការផ្លាស់ប្តូរទៅតាមស្ថានភាពជាក់ស្តែង។*

ករណីអ្នកចូលរួមបង្ហាញថាខ្លួនជាអ្នកប្រព្រឹត្តអំពើហិង្សា អ្នកសម្របសម្រួលត្រូវឆ្លើយតបដោយអារម្មណ៍ស្ងប់ រក្សានូវសេចក្តីថ្លៃថ្នូររបស់អ្នកចូលរួម និងមិនបង្ហាញពីការប្រតិកម្មផ្សេងៗ ដែលអាចប៉ះពាល់ដល់អ្នកចូលរួមដោយប្រការណាមួយនោះទេ។ អ្នកសម្របសម្រួលត្រូវព្យាយាមរក្សានូវគោលជំហនៃគោលការណ៍មិនគាំទ្រ និងមិនលើកលែងដល់ការប្រើប្រាស់អំពើហិង្សាគ្រប់រូបភាព ព្រមទាំងមិនពង្រឹងនូវផ្នត់គំនិតដែលបង្កគ្រោះថ្នាក់ទាំងឡាយ ប៉ុន្តែស្របពេលជាមួយគ្នាគឺត្រូវធានាថាមិនមានការវាយប្រហារកើតមានពីសំណាក់អ្នកចូលរួមដទៃទៀត។ ក្នុងស្ថានភាពនេះ ប្រហែលជាមិនសមប្រកបក្នុងការជជែកដេញដោលលំអិតនៅក្នុងក្រុមធំជាមួយនឹងអ្នកចូលរួមដទៃទៀតឡើយ។ អ្នកសម្របសម្រួលអាចបន្តការជួបផ្ទាល់ជាមួយអ្នកចូលរួមទាំងនោះ ដោយមានវត្តមានរបស់អ្នកសម្រួលសម្រួលផ្សេងទៀត ដើម្បីជជែកលំអិតឡើងវិញពីអាកប្បកិរិយាគ្រោះថ្នាក់ទាំងនោះ និងសង្កត់ធ្ងន់លើប្រព័ន្ធច្បាប់ទាំងឡាយដែលពាក់ព័ន្ធ ប៉ុន្តែត្រូវចាំថាមិនត្រូវស្តីបន្ទោសទៅកាន់ពួកគេឡើយ។ បន្ទាប់ពីការជជែក អ្នកសម្របសម្រួលត្រូវចងក្រងព័ត៌មាន និងភ្ជាប់អ្នកចូលរួមទៅកាន់អ្នកអន្តរាគមន៍ដែលមានស្រាប់ក្នុងសហគមន៍ ដូចជាមន្ត្រីនគរបាល ឬជនបង្គោលបុរសឃុំដែលទទួលបន្ទុកកិច្ចការទាំងនោះទៅតាមស្ថានភាពចាំបាច់។

*កិច្ចពិភាក្សាបុរស គឺជាការពិភាក្សាសម្ងាត់មួយ ដែលអ្នកចូលរួមត្រូវបានស្នើសុំឱ្យរក្សារឿងរ៉ាវផ្ទាល់ខ្លួនដែលពួកគេបានពិភាក្សាក្នុងការប្រជុំសម្រាប់តែខ្លួនឯង ដោយមិនត្រូវផ្សព្វផ្សាយរឿងរ៉ាវទាំងនោះទៅអ្នកដទៃទៀតក្នុងសហគមន៍នោះទេ។ គោលការណ៍នេះធ្វើឡើងដើម្បីផ្តល់ការគោរពដល់បុគ្គលម្នាក់ៗ និងជៀសវាងការបង្កើតភាពមិនទុកចិត្តគ្នាក្នុងចំណោមក្រុមបុរស ឬអាចឈានទៅការបង្កគ្រោះថ្នាក់ដោយផ្ទាល់ក៏មាន។*

## ៨.៣ កិច្ចការពារសុវត្ថិភាពកុមារ

កិច្ចការពារសុវត្ថិភាពកុមារ គឺការធានាឱ្យកុមារគ្រប់រូបមានសុវត្ថិភាពពីគ្រោះថ្នាក់ផ្សេងៗ ដែលអាចបង្កឡើងដោយអ្នកសម្របសម្រួលទាំងចេតនា ឬអចេតនា។ អ្នកសម្របសម្រួលមានតួរនាទីយ៉ាងសំខាន់ក្នុងការធានាឱ្យមានកន្លែងសុវត្ថិភាព និងគួរឱ្យគោរពសម្រាប់អ្នកចូលរួមទាំងអស់ រួមទាំងកុមារដែលអាចមានវត្តមាន សូម្បីតែក្នុងអំឡុងពេលពិភាក្សាដែលផ្តោតលើមនុស្សពេញវ័យក៏ដោយ។ កិច្ចការពារសុវត្ថិភាពកុមារអាចជួយអ្នកសម្របសម្រួលក្នុងការទទួលស្គាល់ និងការពារហានិភ័យដែលអាចកើតមាន តាមរយៈការប្រព្រឹត្តអាកប្បកិរិយាសមរម្យជាគំរូភាព និងការឆ្លើយតបដោយការទទួលខុសត្រូវចំពោះក្តីកង្វល់ទាំងឡាយ។ វាក៏រួមចំណែកបង្កើនជំនឿទុកចិត្ត ធានាការអនុលោមតាមច្បាប់ និងការអនុវត្តក្រមសីលធម៌ ព្រមទាំងពង្រឹងសុចរិតភាពនៃដំណើរការកិច្ចពិភាក្សាទាំងមូល។

- ❖ បង្កើនចំណេះដឹងអំពីកិច្ចការពារសុវត្ថិភាពកុមារ

អ្នកសម្របសម្រួលគួរតែស្វែងយល់ឱ្យបានច្បាស់លាស់អំពីការការពារសុវត្ថិភាពកុមារ ពីព្រោះក្នុងនាមជាអ្នកសម្របសម្រួល គឺមិនមែនត្រឹមតែជាអ្នកដឹកនាំការពិភាក្សាប៉ុណ្ណោះទេ ប៉ុន្តែគឺជាអ្នកផ្តល់គំរូភាពនៃឥរិយាបថ និងអាកប្បកិរិយាទៅកាន់មនុស្សជុំវិញខ្លួន។ អ្នកសម្របសម្រួលមានទំនួលខុសត្រូវក្នុងការលើកកម្ពស់នូវសុវត្ថិភាព ការគោរព និងការការពារកុមារក្នុងកិច្ចពិភាក្សាទាំងមូល ធានាថាខ្លួនមិនបង្កគ្រោះថ្នាក់គ្រប់រូបភាពដល់កុមារដែលរួមមាន អំពើហិង្សា និងការរំលោភបំពាន ការកេងប្រវ័ញ្ច ការផាត់កុមារចោល ឬ ការរើសអើងនានា។

- ❖ គ្រប់គ្រងហានិភ័យពីការរំលោភបំពាន និងកេងប្រវ័ញ្ចលើកុមារ

ការគ្រប់គ្រងហានិភ័យមានន័យថា ការកំណត់ទំហំនៃឧប្បត្តិហេតុ ឬគ្រោះថ្នាក់ដែលអាចកើតឡើងជាមុនដើម្បីចាត់វិធានការ កាត់បន្ថយ ផលជះ ឬភាពធ្ងន់ធ្ងរនៃការកើតឡើងនោះ។ អ្នកសម្របសម្រួលត្រូវយកចិត្តទុកដាក់ខ្ពស់បំផុតរាល់គ្រប់កង្វល់ បញ្ហាប្រឈម ឬឧប្បត្តិហេតុដែលអាចកើតឡើង ឬអាចបង្កជាហានិភ័យចំពោះកុមារ។ ការបង្ការទំនាស់ដល់កុមារ គឺត្រូវកំណត់ជាអាទិភាពតាមរយៈការវាយតម្លៃគ្រប់ជ្រុងជ្រោយ និងការកាត់បន្ថយហានិភ័យនានានៅមុនពេល កំឡុងពេល និងក្រោយពេលរៀបចំកិច្ចពិភាក្សានីមួយៗ។

- ❖ លើកកម្ពស់ការបញ្ជូនសារវិជ្ជមាន និងទប់ស្កាត់បទដ្ឋានសង្គមដែលបង្កគ្រោះថ្នាក់ដល់កុមារ

អ្នកសម្របសម្រួលត្រូវធានាថាការពិភាក្សាគឺប្រកបដោយសារវិជ្ជមានទាក់ទងនឹងកុមារ តាមរយៈការប្រើប្រាស់ពាក្យពេចន៍ដែលមានការគោរព អហិង្សា និងមិនពង្រឹងផ្នត់គំនិតទាំងឡាយណាដែលអាចបង្កគ្រោះ

ថ្នាក់ដល់កុមារ។ សារដែលសមនឹងត្រូវបានបញ្ជ្រាបក្នុងកិច្ចពិភាក្សារួមមាន សុវត្ថិភាព ការគោរព និងការថែទាំ។ ប្រសិនបើមានផ្នត់គំនិត ឬអាកប្បកិរិយាបង្កគ្រោះថ្នាក់កើតឡើង អ្នកសម្របសម្រួលគួរតែកំណត់ឱ្យបានភ្លាមៗ ហើយបកស្រាយដោយភាពស្ងប់ ការគោរព និងក្នុងន័យស្ថាបនា។

### ៨.៣.១ ឥរិយាបថត្រូវធ្វើ និងមិនត្រូវធ្វើក្នុងកិច្ចការពារសុវត្ថិភាពកុមារ

**⃠ ឥរិយាបថដែលត្រូវធ្វើ**

- ប្រព្រឹត្តចំពោះកុមារដោយមានភាពថ្លៃថ្នូរ និងការគោរពដោយមិនគិតពីអត្តសញ្ញាណ ដូចជាជនជាតិភាគតិច ពូជសាសន៍ ភេទ អាយុ វណ្ណៈ ភាសា សាសនា ពិការភាព ស្ថានភាពសង្គម សេដ្ឋកិច្ច ឬ ស្ថានភាពផ្សេងៗទៀត។
- លើកឡើងពីការព្រួយបារម្ភភ្លាមៗអំពីសុវត្ថិភាព ឬសុខុមាលភាពរបស់កុមារ និងធានាបាននូវសមធម៌នៅពេលរួមបញ្ចូលពួកគេក្នុងការសម្រេចចិត្តផ្សេងៗ។
- ស្តាប់កុមារ និងអនុញ្ញាតឱ្យពួកគេចូលរួមក្នុងការសម្រេចចិត្ត ជាពិសេសនៅពេលដែលការសម្រេចចិត្តត្រូវបានធ្វើឡើងដែលទាក់ទងនឹងសុខុមាលភាពផ្ទាល់ខ្លួនរបស់ពួកគេ។
- អនុវត្តតាមច្បាប់ពាក់ព័ន្ធទាំងអស់ក្នុងប្រទេស រួមបញ្ចូលទាំងច្បាប់ការងារដែលទាក់ទងនឹងពលកម្មកុមារ។
- គោរពសេចក្តីថ្លៃថ្នូរ និងសុវត្ថិភាពរបស់កុមារប្រសិនបើពួកគេប្រាប់អ្នកពីរឿងផ្ទាល់ខ្លួន ឬឯកជនភាពរបស់ពួកគេ។
- ទទួលស្គាល់អំណាចរបស់កុមារ ពិភាក្សាជាមួយពួកគេអំពីសិទ្ធិរបស់ពួកគេ អ្វីដែលអាចទទួលយកបាន និងមិនអាចទទួលយកបាន និងអ្វីដែលពួកគេអាចធ្វើបានប្រសិនបើមានបញ្ហាកើតមាន។
- នៅពេលថតកុមារ ឬប្រើរូបភាព ឬវីដេអូរបស់កុមារសម្រាប់គោលបំណងទាក់ទងនឹងការងារត្រូវ៖
    - ទទួលបានការយល់ព្រមពីកុមារ និងឪពុកម្តាយ ឬអាណាព្យាបាលរបស់កុមារ មុនពេលថត ឬកំឡុងពេលថតកុមារ។ ធានាថាបានពន្យល់ពួកគេច្បាស់លាស់អំពីគោលបំណងនៃការប្រើប្រាស់នូវរូបថត ឬវីដេអូទាំងនោះ។
    - ធានានូវរូបថត វីដេអូ និងការបង្ហោះប្រព័ន្ធផ្សព្វផ្សាយសង្គមនានាដែលបានអនុញ្ញាតគឺបង្ហាញកុមារក្នុងលក្ខណៈថ្លៃថ្នូរ និងគួរឱ្យគោរព និងមិនស្ថិតក្នុងលក្ខណៈងាយរងគ្រោះ។ កុមារគួរត្រូវបានស្លៀកពាក់ឱ្យបានគ្រប់គ្រាន់ និងមិនស្ថិតក្នុងឥរិយាបថដែលអាចមើលឃើញថាជាការបង្ហាញផ្លូវភេទ។
    - ធានាថារូបភាពគឺជាតំណាងបរិបទ ស្ថានភាព ឬរឿងរ៉ាវពិត។

- ○ ធានាថាការពិពណ៌នាអត្ថបទផ្សេងៗមិនបង្ហាញព័ត៌មានកំណត់អត្តសញ្ញាណរបស់កុមារ នៅពេលផ្ញើរូបភាពតាមសារអេឡិចត្រូនិក ឬការផ្សព្វផ្សាយរូបភាពនៅក្នុងទម្រង់ណាមួយឡើយ។

### ✔ កិរិយាបថដែលមិនត្រូវធ្វើ

- មិននៅកន្លែងស្ងាត់តែពីរនាក់នៅពេលធ្វើការងារជាមួយកុមារ និងធានាថាមានវត្តមានមនុស្សពេញវ័យ ឬអាណាព្យាបាលកុមារនៅជាមួយ។
- មិនប្រើភាសា ឬបង្ហាញអាកប្បកិរិយាចំពោះកុមារដែលមិនសមរម្យ បៀតបៀន រំលោភបំពាន ការបង្ខូចកេរ្តិ៍ឈ្មោះ ញុះញង់ផ្លូវភេទ ឬវប្បធម៌មិនសមរម្យ។
- មិននាំកុមារចូលរួមក្នុងទម្រង់នៃសកម្មភាពណាមួយដែលបង្ខូចកេរ្តិ៍ឈ្មោះ ប្រមាថ បង្ករឿងរ៉ាវទាក់ទងនឹងផ្លូវភេទ រំលោភបំពាន ឬវប្បធម៌មិនសមរម្យផ្សេងៗ។
- មិនបញ្ចូលកុមារក្នុងទម្រង់នៃសកម្មភាពផ្លូវភេទ ឬសកម្មភាពណាមួយ រួមទាំងការបង់ប្រាក់សម្រាប់សេវាផ្លូវភេទ ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀត។
- មិននាំកុមារដែលមិនមានអ្នកនៅជាមួយទៅផ្ទះរបស់ពួកគេ លុះត្រាតែពួកគេមានគ្រោះថ្នាក់ភ្លាមៗនៃការរងរបួស ឬមានគ្រោះថ្នាក់ដល់រាងកាយនានា។
- មិនចូលប្រើ ឬមើលរូបភាពអាសអាភាសរបស់កុមារតាមប្រភពផ្សេងៗ។
- មិនគេងនៅជិតកុមារដែលមិនមានអ្នកនៅជាមួយ។
- មិនជួលកុមារធ្វើការងារពលកម្មផ្សេងៗ ដែលមិនសមស្របទៅតាមអាយុ ឬដំណាក់កាលនៃការអភិវឌ្ឍន៍ ដែលរំខានដល់ពេលវេលារបស់ពួកគេសម្រាប់ការអប់រំ និងសកម្មភាពកម្សាន្ត ឬធ្វើឱ្យពួកគេប្រឈមមុខនឹងការរងរបួសធ្ងន់ធ្ងរ។
- មិនផាត់កុមារចេញ ឬគិតគូរតែចំពោះកុមារណាដែលខ្លួនចូលចិត្ត។
- មិនប្រើឧបករណ៍រួមមានកុំព្យូទ័រ ទូរសព្ទ កាមេរ៉ា ដើម្បីថតរូបភាពមិនសមរម្យ និងដោយគ្មានការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលរបស់កុមារ។
- មិនវាយដំលើរាងកាយ ការប្រៀនប្រដៅ ឬដាក់ទណ្ឌកម្មកុមារ។
- មិនប៉ះពាល់រាងកាយកុមារក្នុងលក្ខណៈមិនសមរម្យ ឬមិនសមស្របតាមវប្បធម៌។

# ៩. ការត្រួតពិនិត្យ និងការវាយតម្លៃ

ការត្រួតពិនិត្យ និងវាយតម្លៃគឺជាផ្នែកមួយដ៏សំខាន់នៃការអនុវត្តកិច្ចពិភាក្សាបុរស ដើម្បីស្វែងយល់អំពីប្រសិទ្ធភាព ការគិតគូរពីបរិយាបន្ន និងផលជះរបស់វា។ ការត្រួតពិនិត្យ និងវាយតម្លៃនេះផងដែរគឺគួរតែត្រូវបានរៀបចំ និងអនុវត្តជាបីដំណាក់កាល រួមមានមុនពេល អំឡុងពេល និងក្រោយពេលកិច្ចពិភាក្សានីមួយៗ។ វិធីសាស្ត្រនេះនឹងជួយអ្នកសម្របសម្រួលក្នុងការវាយតម្លៃពីប្រសិទ្ធភាពទទួលបាន កម្រិតនៃការចូលរួម ការឆ្លើយតបនឹងបរិយាបន្ន បញ្ហាប្រឈម និងចំណុចដែលត្រូវកែលម្អឱ្យកាន់តែប្រសើរនៅពេលខាងមុខ។

## ៩.១ គោលបំណងចម្បងនៃការត្រួតពិនិត្យ និងវាយតម្លៃ

- ដើម្បីពិនិត្យមើលថា តើកិច្ចពិភាក្សាបានសម្រេចទៅស្របតាមគោលដៅដែលបានកំណត់ដែរឬទេ
- ស្វែងយល់ពីបទពិសោធន៍ និងកម្រិតនៃការចូលរួមរបស់អ្នកចូលរួមមកពីគ្រប់ចម្រុះភាព
- កំណត់ពីចំណុចខ្លាំង ចំណុចខ្សោយ និងផ្នែកដែលត្រូវកែលម្អទៅថ្ងៃខាងមុខ
- ដើម្បីធានាបាននូវបរិយាបន្ន និងបង្កលក្ខណៈងាយស្រួលសម្រាប់អ្នកចូលរួមគ្រប់ចម្រុះភាព
- ពង្រឹងគណនេយ្យភាព និងការជឿទុកចិត្តជាមួយអ្នកចូលរួម និងនៅក្នុងសហគមន៍ទាំងមូល។

## ៩.២ នៅមុនពេលចាប់ផ្តើមកិច្ចពិភាក្សាបុរស

នៅមុនពេលចាប់ផ្តើមអនុវត្តកិច្ចពិភាក្សាបុរស អ្នកសម្របសម្រួលត្រូវកំណត់គោលបំណង និងលទ្ធផលរំពឹងទុកពីកិច្ចពិភាក្សាឱ្យបានច្បាស់លាស់។ វានឹងជួយធានាបានថាការពិភាក្សាគឺប្រព្រឹត្តទៅដោយរលូន សម្រេចបានតាមអ្វីដែលបានកំណត់ ព្រមទាំងស្របទៅនឹងតម្រូវការ ឬបញ្ហារបស់អ្នកចូលរួមកំពុងតែជួបប្រទះ។ នៅដំណាក់កាលនេះ អ្នកសម្របសម្រួលគួរតែ៖

- ពិនិត្យពីគោលបំណងនៃការពិភាក្សា និងលទ្ធផលរំពឹងទុក
- ស្វែងយល់ និងកំណត់ពីសមាសភាពនៃអ្នកចូលរួម (បរិបទទូទៅរបស់ក្រុមអ្នកចូលរួម)
- ពិនិត្យ និងវាយតម្លៃលើតម្រូវការ ចំណេះដឹង និងការរំពឹងទុកពីអ្នកចូលរួម
- រៀបចំភស្តុភារដែលមានបរិយាបន្ន និងបង្កលក្ខណៈងាយស្រួល (ទីកន្លែង ពេលវេលា សម្ភារៈអ្នក មើលថែកុមារ ប្រសិនបើអាចធ្វើទៅបាន)
- ត្រៀមជាមុននូវកម្រងសំណួរសម្រាប់ការអង្កេត ឆ្លុះបញ្ចាំង និងប្រមូលមតិត្រឡប់សម្រាប់កែលម្អ។

## ៩.៣ ក្នុងអំឡុងពេលកិច្ចពិភាក្សាបុរស

ក្នុងអំឡុងពេលពិភាក្សា អ្នកសម្របសម្រួលគួរតែសង្កេត កត់សម្គាល់ ឬចងក្រងឯកសារអំពីការប្រព្រឹត្តទៅរបស់កិច្ចពិភាក្សាទាំងមូល។ ចំណុចសំខាន់គឺការផ្តោតលើកម្រិតនៃការចូលរួម បរិយាបន្ន គុណភាពនៃការសម្របសម្រួល និងភាពខុសគ្នានៃអំណាច ជាជាងការផ្តោតតែទៅលើខ្លឹមសារនៃកិច្ចពិភាក្សា។ ការតាមដាន និងត្រួតពិនិត្យក្នុងអំឡុងពេលកិច្ចពិភាក្សាគឺអាចឱ្យអ្នកសម្របសម្រួលកែប្រែនូវវិធីសាស្ត្រដ៏មានប្រសិទ្ធភាពបានទាន់ពេលវេលា ជាពិសេសស្របតាមវិធីសាស្ត្រសម្របសម្រួលបែបហ្វេមមីនីស្ត។

ផ្នែកដែលអ្នកសម្របសម្រួលអាចសង្កេត និងកត់សម្គាល់រួមមាន៖

- ចំនួនអ្នកចូលរួមដែលចូលរួមសកម្ម និងអ្នកដែលស្ងៀមស្ងាត់
- កម្រិតនៃការចូលរួម ថាមពល និងការប្រាស្រ័យ ឆ្លើយតបគ្នា
- សុវត្ថិភាព និងការគោរពគ្នាក្នុងចំណោមអ្នកចូលរួម
- ការដោះស្រាយទៅនឹងភាពរសើប និងជម្លោះ
- លំហូរនៃការពិភាក្សាទៅតាមគោលបំណង និងការគ្រប់គ្រងពេលវេលា។

## ៩.៤ បន្ទាប់ពីកិច្ចពិភាក្សាបុរស

បន្ទាប់ពីកិច្ចពិភាក្សាបានបញ្ចប់ អ្នកសម្របសម្រួលគួរតែផ្តោតលើចំណុចដូចខាងក្រោម៖

- ប្រមូលមតិស្ថាបនារបស់អ្នកចូលរួម (តាមរយៈការស្ទង់មតិខ្លីៗ លំហាត់ឆ្លុះបញ្ចាំង ឬការចែករំលែកជាក្រុម)
- ត្រួតពិនិត្យមើលថា តើអ្នកចូលរួមមានអារម្មណ៍ថាមានសុវត្ថិភាព បានរួមបញ្ចូល និងគោរពដែរ ឬទេ
- ពិនិត្យមើលថា តើវិធីសាស្ត្រនៃការពិភាក្សាបានផ្តល់ឱកាសស្មើគ្នាក្នុងការនិយាយ និងរួមចំណែកចូលដែរ ឬទេ
- កំណត់គន្លឹះសំខាន់ៗ សារ/សម្រង់ពាក្យសម្តី ការផ្លាស់ប្តូរលើការដឹង សកម្មភាព និងអាកប្បកិរិយា
- កត់ត្រាលទ្ធផលដូចជា ការកើនឡើងនូវទំនុកចិត្ត សាមគ្គីភាព ឬទំនាក់ទំនងដែលបានបង្កើតឡើង។

## ៩.៥ សូចនាករ

ការវាស់វែងប្រកបដោយប្រសិទ្ធភាពនៃកិច្ចពិភាក្សាបុរសទាមទារឱ្យមានសូចនាករច្បាស់លាស់នៃចម្រុះភាព ការចូលរួម ភាពងាយស្រួល និងគុណភាពនៃការទំនាក់ទំនង។ សូចនាករដែលបានណែនាំរួមមាន៖

- ភាពចម្រុះនៃអ្នកចូលរួម (អាយុ និន្នាការភេទ ប្រវត្តិ ពិការភាព ។ល។)
- ការចូលរួមយ៉ាងសកម្ម និងការចូលរួមស្មើៗគ្នានៅក្នុងកន្លែងដែលមានភាពងាយស្រួលចូលរួមបាន និងកន្លែងសុវត្ថិភាព
- អ្នកចូលរួមរាយការណ៍ពីការបង្កើនទំនុកចិត្ត និងការយល់ដឹងអំពីបញ្ហាយេនឌ័រ
- ការបង្កើតសាមគ្គីភាព និងសកម្មភាពរួមក្នុងចំណោមអ្នកចូលរួម
- ភស្តុតាង ឬទិន្នន័យដែលទទួលបានពីមតិកែលម្អ ដើម្បីឱ្យកិច្ចពិភាក្សាបុរសមានដំណើរការល្អនាពេលអនាគត។

រៀបរៀងដោយ៖ អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា





www.gadc.org.kh

+៨៥៥ (0)៩៦ ៣២៥ ១៦៩០

ផ្ទះលេខ #៣៩B ផ្លូវ#៦០៨ សង្កាត់បឹងកក់២ ខណ្ឌទួលគោក ភ្នំពេញ



គាំទ្រដោយ

Sweden Sverige

Save the Children